# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី១ លេខ១ ត្រីមាសទី១ ឆ្នាំ២០២៤



អគ្គលេខាធិការដ្ឋាននៃសមាគមឧកញ៉ាកម្ពុជា

# មាតិកា


- ប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមបេសកកម្ម «គោះទ្វារវិនិយោគ» នៅប្រទេសចិន................................១
- ពិធីក្រាបថ្វាយបង្គំគាល់ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី.................................................................៣
- កិច្ចប្រជុំលើកដំបូងនៃគ.ព.វ.គ..........................................................................................................៦
- ពិធីប្រកាសជាផ្លូវការ«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤...............................៧
- ជំនួបជាមួយថ្នាក់ដឹកនាំសភាពាណិជ្ជកម្មនិងឧស្សាហកម្មជប៉ុន...........................................................៨
- ជំនួបពិភាក្សាធុរកិច្ចនិងបេសកកម្មនានានៅក្នុងព្រះរាជាណាចក្រថៃឡង់ដ៍..........................................១០
- កម្មវិធីសប្បុរសធម៌នៅសាលាអនុវិទ្យាល័យស្ទឹងជ្រៅ..........................................................................១៣
- កម្មវធីសប្បុរសធម៌នៅខេត្តកំពង់ស្ពឺ.....................................................................................................១៥
- ពិធីប្រកាសជាផ្លូវការនៃក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា.....................................................................១៧
- កិច្ចប្រជុំធុរកិច្ចជាមួយឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌា........................................១៩
- កិច្ចប្រជុំធុរកិច្ចជាមួយឯកឧត្តមឧត្តមសេនីយ៍ឯក James L. Jones....................................................២០
- កម្មវិធីផ្សព្វផ្សាយ «ការសាងសង់សួនតេជោសន្តិភាព»...........................................................................២២
- ពិធីបុណ្យផ្កាប្រាក់សាមគ្គីជាតិដើម្បីកសាងពុទ្ធប្បដិមាកម្ពស់ ១០៨ម៉ែត្រ...............................................២៣
- កិច្ចប្រជុំស្តីពី «តំបន់សេដ្ឋកិច្ចពិសេសបំពេញបន្ថែមគ្នារវាងកម្ពុជា-ថៃ»...................................................២៤
- ចូលរួមគោរពវិញ្ញាណក្ខន្ធឪពុកបង្កើតរបស់ អ្នកឧកញ៉ា អ៊ឹង លីហេង........................................................២៥
- កិច្ចប្រជុំធុរកិច្ចជាមួយលោកជំទាវឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅកម្ពុជា.....................................................២៦
- កម្មវិធី " India-Cambodia Chemical Business Meet"........................................................................២៧
- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៨..................................................................................................២៨
- ជំនួបធុរកិច្ចជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា............................................................៣០
- ពិធីសម្ពោធ«ពិព័រណ៌គ្រឿងអលង្ការនិងត្បូងកម្ពុជា-អន្តរជាតិលើកទី១៥ឆ្នាំ២០២៤»..............................៣១
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិសាមញ្ញលើកទី៧ អាណត្តិទី១.................................................................៣២

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមបេសកកម្ម "គោះទ្វារវិនិយោគ" នៅសាធារណរដ្ឋប្រជាមានិតចិន

ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដឹកនាំគណៈប្រតិភូក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមទាំងមានការចូលរួមអមដំណើរពីគណៈប្រតិភូជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជាដូចជា អ្នកឧកញ៉ា លាង ឃុន អ្នកឧកញ៉ា វិញ ហ៊ួរ អ្នកឧកញ៉ា ឡាង កាង និងអ្នកឧកញ៉ា ទី ពិសិដ្ឋ ធ្វើទស្សនកិច្ចនៅក្រុងឈីងតាវ ខេត្តសានដុង ប្រទេសចិន រយៈប្រមាណ៤ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤។ ទស្សនកិច្ចនេះ ត្រូវបានដាក់ឈ្មោះថា **«គោះទ្វារវិនិយោគ»** ពោលជាដំណើរទស្សនកិច្ចមួយដើម្បីបញ្ចុះបញ្ចូល និងអូសទាញអ្នកវិនិយោគនៅក្រុងឈីងតាវឱ្យមកវិនិយោគនៅកម្ពុជា ។

ក្នុងរយៈពេលនៃបេសកកម្មនេះគណៈប្រតិភូកម្ពុជាបានអញ្ជើញទស្សនកិច្ចតាមបណ្ដារោងចក្រក៏ដូចជាក្រុមហ៊ុនធំៗជាច្រើនដូចជា៖ សម្ព័ន្ធ Sailun Group Co., Ltd. មន្ទីរពិសោធន៍ Stonelab សាលពិព័រណ៍មជ្ឈមណ្ឌលកៅស៊ូជាតិ ក្រុមហ៊ុន MESNAC ក្រុមហ៊ុន KenGic គឺជាក្រុមហ៊ុនដែលប្រតិបត្តិការលើដំណោះស្រាយប្រព័ន្ធផលិតកម្មឆ្លាតវៃការដឹកជញ្ជូនឆ្លាតវៃនិងក៏ជាមូលដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍ឌីជីថលប្រកបដោយភាពច្នៃប្រឌិតដែលផ្គត់ផ្គង់គ្រឿងចក្រទៅបណ្ដាក្រុមហ៊ុនធំៗនៅលើពិភពលោកនិងប្រមាណជាង២០ប្រទេសក្នុងតំបន់អាស៊ីរួមទាំងកម្ពុជាផងដែរ, ក្រុមហ៊ុន Kinger Robot គឺជាសហគ្រាសបច្ចេកវិទ្យាកម្រិតខ្ពស់ ដែលប្រតិបត្តិការរចនា ការផលិត ការលក់ និងសេវាកម្មឧបករណ៍ឆ្លាតវៃរបស់មនុស្សយន្តប្រព័ន្ធរោងចក្រឆ្លាតវៃនិងប្រព័ន្ធឃ្លាំងនិងប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃដែលបានផ្គត់ផ្គង់ផលិតផលទៅក្រុមហ៊ុនធំៗជាច្រើនមានជាអាទិ៍ក្រុមហ៊ុន Huawei ក្រុមហ៊ុន Ford និងក្រុមហ៊ុន Toyota ជាដើម។













ក្នុងឱកាសនោះដែរឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបញ្ជាក់អំពីជំហររបស់កម្ពុជាក្នុងការបើកទទួលរាល់វិនិយោគិនទាំងអស់ និងពិសេសលើកទឹកចិត្តចំពោះក្រុមហ៊ុនក្នុងការពង្រីកខ្សែច្រវាក់ផលិតកម្មរបស់ខ្លួននៅកម្ពុជាបន្ថែមទៀតឯកឧត្តមក៏បានបង្ហាញអំពីទិសដៅរបស់កម្ពុជាដែលចង់ឃើញមានការវិនិយោគលើវិស័យនានានៅកម្ពុជា ដែលនេះស្របទៅគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ការខិតខំឱ្យកម្ពុជាជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ដោយត្រូវប្តូរមកប្រើធនធានបច្ចេកទេសខ្ពស់ការប្រើប្រាស់បច្ចេកវិទ្យាជាដើម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានបន្តថា កម្ពុជាមានសុខសន្តិភាពពេញលេញក្រោមការខិតខំប្រឹងប្រែងរបស់ សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងការខិតខំថែរក្សាបន្តទៀតរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា ដែលអនុញ្ញាតឱ្យសេដ្ឋកិច្ចកម្ពុជាអាចរីកចម្រើនបានក្នុងរង្វង់៧ភាគរយមុនពេលកើតមានជំងឺកូវីដ១៩, ៥,៣ភាគរយក្នុងឆ្នាំ២០២៣ និងរំពឹងថាកើនឡើង៦,៣ភាគរយក្នុងឆ្នាំ២០២៤។ បន្ថែមពីលើនេះកម្ពុជាមានយុវជនវ័យក្មេងអាយុក្រោម២៥ឆ្នាំ ជាង៦០ភាគរយដែលកត្តាធនធានមនុស្សនេះនឹងជួយជំរុញសេដ្ឋកិច្ចកម្ពុជាបន្ថែមទៀត ស្របតាមគន្លឹះអាទិភាពរួមមានផ្លូវ ភ្លើង ទឹក ធនធានមនុស្ស និងបច្ចេកវិទ្យា។ ចំពោះហេដ្ឋារចនាសម្ព័ន្ធកម្ពុជាមានផ្លូវតភ្ជាប់ពាសពេញផ្ទៃប្រទេសមានផ្លូវតភ្ជាប់ទៅប្រទេសជិតខាងផ្លូវល្បឿនភ្នំពេញក្រុងព្រះសីហនុ ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត ផ្លូវល្បឿនលឿនភ្នំពេញ-សៀមរាប-ប៉ោយប៉ែត គម្រោងលើកកម្រិតផ្លូវរថភ្លើងភ្នំពេញ-ក្រុងព្រះសីហនុ គម្រោងកែលម្អផ្លូវរថភ្លើងភ្នំពេញ-ប៉ោយប៉ែត គម្រោងសិក្សាផ្លូវដែកថ្មីភ្នំពេញ-បាវិត គម្រោងសាងសង់កំពង់ផែទឹកជ្រៅក្រុងព្រះសីហនុ គម្រោងសាងសង់កំពង់ផែកំពត គម្រោងសាងសង់កំពង់កោះកុង គម្រោងព្រែកជីកហ្វូណនតេជោ និងគម្រោងផែនការមេភ័ស្តុភារកម្មជាដើម។

លើសពីនេះរាជរដ្ឋាភិបាលចាត់ទុកផ្នែកឯកជនជាដៃគូរដ៏សំខាន់ដោយក្នុងនោះមានរៀបចំបង្កើតក្រុមការងារចំនួន១៤ពីវិស័យរដ្ឋនិងឯកជនដើម្បីធ្វើការរួមគ្នាដោះស្រាយបញ្ហានានារបស់វិស័យឯកជន។កម្ពុជាមានច្បាប់វិនិយោគដែលផ្តល់ការលើកទឹកចិត្តដល់គ្រប់វិនិយោគិនដែលដាក់ទុនវិនិយោគនៅកម្ពុជាហើយក្នុងនោះមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាអ្នកទាក់ទាញ សម្របសម្រួល និងថែទាំគម្រោង វិនិយោគទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ពិធីក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី

នាព្រឹកថ្ងៃសៅរ៍ ១០កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានសព្វព្រះរាជហឫទ័យ ព្រះបរមរាជានុញ្ញាតដល់ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ២០០រូប ចូលក្រាបថ្វាយបង្គំគាល់នាព្រះរាជដំណាក់សិរីមង្គលនៃព្រះបរមរាជវាំង។



នេះពិតជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងជាលើកដំបូងបំផុតសម្រាប់សមាគមឧកញ៉ាកម្ពុជាដែលថ្នាក់ដឹកនាំរួមទាំងសមាជិកដែលមានគោរមងារជាអ្នកឧកញ៉ានិងឧកញ៉ារហូតដល់ទៅ២០០រូបទទួលបាននូវព្រះបរមរាជានុញ្ញាតនិងមហាកិត្តិយសចូលក្រាបថ្វាយបង្គំគាល់ក្នុងគ្រាតែមួយជាមួយគ្នាបែបនេះនិងជាលើកដំបូងដែលបានប្រើប្រាស់ឯកសណ្ឋានផ្លូវការនៃគោរមងារឧកញ៉ាដែលត្រូវបានចែងយ៉ាងច្បាស់ក្នុងព្រះរាជក្រឹត្យលេខ **នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពី «គោរមងារឧកញ៉ា»**។

មុននឹងប្រោសព្រះរាជទាននូវព្រះរាជសវនាការដ៏វិសេសវិសាលនេះ ព្រះអង្គទាំងទ្វេ បានប្រោសព្រះរាជទានអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវ ព្រមទាំង អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលក្រាបថ្វាយបង្គំនិងថ្វាយគ្រឿងសក្ការៈបូជាថ្វាយព្រះបរមរូបព្រះករុណាព្រះមហាវីរក្សត្រព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ នាបរិវេណខាងមុខព្រះរាជដំណាក់គន្ធបុប្ផា។







ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រកបដោយមហាកិត្តិយសនេះ អ្នកឧកញ៉ា លី យ៉ុងផាត់ បានទូលថ្វាយនូវសកម្មភាពជាច្រើននាពេលកន្លងមករបស់សមាគមឧកញ៉ាកម្ពុជាទាំងលើវិស័យសង្គមកិច្ច អប់រំ មនុស្សធម៌ សុខាភិបាល និងផ្នែកពុទ្ធចក្រ ព្រមទាំងការជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគស្របទៅតាមចក្ខុវិស័យ និងបេសកកម្មរបស់សមាគមដែលមានការទទួលស្គាល់ពេញលេញតាមផ្លូវច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ទន្ទឹមនឹងនេះក៏បានថ្វាយនូវព្រះរាជតង្វាយរួមមានអង្ករសរុប ១១០តោននិងថវិកាសរុបចំនួន ១លានដុល្លារអាម៉េរិកដើម្បីចូលរួមដង្ហែក្នុងព្រះរាជសកម្មភាពសប្បុរសធម៌ដ៏ឧត្តុង្គឧត្តមប្រកបដោយទសពិធរាជធម៌របស់ព្រះអង្គទាំងទ្វេដែលតែងតែមានព្រះរាជហឫទ័យខ្វល់ខ្វាយជាប់ជានិច្ចអំពីសុខទុក្ខរបស់ប្រជារាស្ត្រជាកូនជាចៅរបស់ព្រះអង្គ។

ក្នុងវរោកាសដ៏ប្រពៃថ្លៃថ្លានេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានមានព្រះរាជបន្ទូលកោតសរសើរចំពោះកិច្ចខំប្រឹងប្រែងរបស់អ្នកឧកញ៉ាលីយ៉ុងផាត់ក្នុងការដឹកនាំសមាគមឧកញ៉ាកម្ពុជាទទួលបាននូវភាពជោគជ័យជាច្រើននាពេលកន្លងមកក៏ដូចជារួបរួមសាមគ្គីរបស់អ្នកឧកញ៉ានិង ឧកញ៉ាដែលជាសមាជិកសមាគមក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចនិងបង្កើតការងារជាច្រើនសែនកន្លែងដល់ប្រជាជនកម្ពុជាតាមរយៈការវិនិយោគនិងសកម្មភាពជំនួញនានាស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជាពិសេសព្រះអង្គទាំងទ្វេជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតបានមានព្រះបរមរាជឱង្ការផ្តាំផ្ញើដល់អ្នកឧកញ៉ានិងឧកញ៉ាទាំងអស់ សូមចូលរួមថែរក្សាការពារប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ខ្មែរដើម្បីធានាបាននូវសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ព្រមទាំងបានប្រោសព្រះរាជទានពរជ័យដល់សមាជិកសមាគមឧកញ៉ាកម្ពុជាគ្រប់ៗរូប សូមទទួលបានភាពជោគជ័យ វិបុលសុខ គ្រប់ប្រការ និងបានសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានវរោកាសដល់អ្នកឧកញ៉ានិងឧកញ៉ាទាំងអស់បានថតរូបភាពជាអនុស្សាវរីយ៍ផងដែរ។

















# កិច្ចប្រជុំលើកដំបូងនៃគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា ( គ.ព.វ.គ )

នាព្រឹកថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ អ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជារួមជាមួយអ្នកឧកញ៉ា ហ៊ុន ឡាក់ ជាអគ្គលេខាធិការដែលតំណាងឱ្យសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា ( **គ.ព.វ.គ** ) ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។របៀបវារៈនៃកិច្ចប្រជុំលើកដំបូងគឺ ពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការត្រួតពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា។

អង្គប្រជុំបានធ្វើការពិនិត្យពិភាក្សានិងផ្តល់យោបល់ដែលជាធាតុចូលដ៏សំខាន់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា ដោយបានពិនិត្យលើគ្រប់ទិដ្ឋភាពក្នុងនោះមានទិដ្ឋភាពច្បាប់និងទិដ្ឋភាពជាក់ស្តែងព្រមទាំងពិនិត្យលើឯកសារគាំទ្រផ្សេងៗជាគតិយុត្តិជាពិសេសយោងទាំងស្រុងតាមខ្លឹមសារ និងមាត្រានានានៃព្រះរាជក្រឹត្យលេខ **នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា** ដោយសេចក្តីព្រាងអនុក្រឹត្យនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការស្នើសុំ និងការវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា ទំហំទឹកប្រាក់នៃអំណោយ និងវិភាគទានរបកគំហើញបច្ចេកវិទ្យាថ្មីៗឬស្នាដៃពិសេសព្រមទាំងបែបបទនិងនីតិវិធីនៃការបញ្ចប់គោរមងារឧកញ៉ាដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ ទំនៀមទម្លាប់ ប្រពៃណីល្អ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។












## ពិធីប្រកាសជាផ្លូវការនូវ “កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤”

នាព្រឹកថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំអ្នកឧកញ៉ា និងឧកញ៉ា ជាអនុប្រធាន និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤**"ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

កម្មវិធីពិសេសនេះជាការដាក់ចេញនូវវិធានការ និងយន្តការ ដែលមានលក្ខណៈជាកញ្ចប់, ប្រទាក់ក្រឡា, មុតស្រួច, និង សាមញ្ញ។ វិធានការគន្លឹះៗក្នុងកម្មវិធីពិសេសនេះមានភាពប្រទាក់ក្រឡាគ្នា និងឆ្លើយតបនឹងស្ថានភាព និងតម្រូវការជាក់ស្តែងចំពោះមុខរបស់ខេត្តព្រះសីហនុក្នុងគោលដៅជំរុញការវិនិយោគ, ការអភិវឌ្ឍឧស្សាហកម្ម, ការស្តារកំណើនសេដ្ឋកិច្ច និង ការបំពេញបន្ថែមលើយុទ្ធសាស្ត្រ និង គោលនយោបាយនានារបស់រាជរដ្ឋាភិបាល, ពិសេសការអនុវត្តផែនការមេ ប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ។










## ជំនួបជាមួយថ្នាក់ដឹកនាំសភាពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន

នារសៀលថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងអនុប្រធាន ព្រមទាំងសមាជិកក្រុមប្រឹក្សាភិបាលសរុបចំនួន១០រូប បានទទួលស្វាគមន៍ លោក Yoshihisa Suzuki ប្រធានគណៈកម្មាធិការកិច្ចសហប្រតិបត្តិការធុរកិច្ចមេគង្គ-ជប៉ុន នៃសភាពាណិជ្ជកម្មនិងឧស្សាហកម្មជប៉ុន និងគណៈប្រតិភូជាន់ខ្ពស់១២រូប នៅរាជធានីភ្នំពេញ ដើម្បីបន្តពិភាក្សាធុរកិច្ច ការវិនិយោគ និងទទួលទានអាហារថ្ងៃត្រង់រួមគ្នា។

ក្នុងនាមជាប្រធាននិងតាងនាមថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាអ្នកឧកញ៉ា លី យ៉ុងផាត់បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោក Yoshihisa Suzuki និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជា និងបានជួបគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដើម្បីរឹតចំណងមិត្តភាព និងភាពជាដៃគូក្នុងវិស័យពាណិជ្ជកម្ម។ អ្នកឧកញ៉ា សៀ ឬទ្ធី បានសង្ខេបជូនគណៈប្រតិភូជប៉ុនអំពីទស្សនវិស័យ និងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជា ដោយរំលេចពី សមាជិកសមាគមគឺជាបង្គុំវិនិយោគិន និងសហគ្រិនធំៗនៅកម្ពុជា ជាពិសេសគឺជាដៃគូវិនិយោគដែលមានគ្រប់វិស័យនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាទាំងមូល។

ជាការឆ្លើយតប លោក Yoshihisa Suzuki បានថ្លែងអំណរគុណ អ្នកឧកញ៉ា លី យ៉ុងផាត់ និងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនិងបានអញ្ជើញគណៈប្រតិភូជប៉ុនពិសាអាហារថ្ងៃត្រង់នៅថ្ងៃនេះ។ លោក Yoshihisa Suzuki បានបន្តថា គណៈកម្មាធិការកិច្ចសហប្រតិបត្តិការធុរកិច្ចមេគង្គ-ជប៉ុន គឺជាគណៈកម្មាធិការអន្តរជាតិមួយនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន ដែលទទួលបន្ទុកក្នុងការប្រមូលព័ត៌មានធ្វើការស្ទង់មតិនិងសិក្សាស្រាវជ្រាវអំពីបរិយាកាសវិនិយោគនិងធុរកិច្ចនៅក្នុងប្រទេសតំបន់មេគង្គរួមទាំងប្រទេសកម្ពុជាផងដែរ ដោយស្ថាប័ននេះគឺជាស្ថាប័នសេដ្ឋកិច្ច និងពាណិជ្ជកម្មដ៏ធំនៅក្នុងប្រទេសជប៉ុន ហើយបច្ចុប្បន្ននេះមានការិយាល័យចំនួន ៥១៥ និងមានសមាជិកសរុបប្រមាណជាង ១,២៥ លាននាក់ដែលផ្តោតសំខាន់លើ វិស័យវាយនភណ្ឌ គ្រឿងម៉ាស៊ីននិងលោហៈធាតុ ថាមពល សារធាតុគីមី អាហារ លំនៅឋាន បច្ចេកវិទ្យាព័ត៌មាន និងហិរញ្ញវត្ថុ។





ទន្ទឹមនឹងនេះ អ្នកឧកញ៉ា លី យ៉ុងផាត់ បានជម្រាបជូនភាគីជប៉ុនដែរថា សមាគមឧកញ៉ាកម្ពុជាកំពុងតែបំពេញការងារយ៉ាងសកម្មក្នុងនាមជាដៃគូរាជរដ្ឋាភិបាលកម្ពុជាលើសកម្មភាព ជំរុញការវិនិយោគនិងពាណិជ្ជកម្ម ក៏ដូចជាទាក់ទាញវិនិយោគិនមកកាន់ប្រទេសកម្ពុជា ដូចនេះ ជំនួបថ្ងៃនេះគឺពិតជាមានសារៈសំខាន់ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងពាណិជ្ជករកម្ពុជា-ជប៉ុនក្នុងការបង្កើតឱកាសវិនិយោគបន្ថែមទៀតនិងបន្តកិច្ចសហប្រតិបត្តិការធុរកិច្ចក្នុងភាពជាដៃគូយូរអង្វែង។

ជំនួបសំណេះសំណាលនេះ បានបញ្ចប់ទៅដោយផ្លែផ្កា ខណៈដែលភាគីទាំងពីរបានកំណត់ថា នឹងបង្កើតចំណងមិត្តភាពព្រមទាំងកិច្ចពិភាក្សាជាបន្តបន្ទាប់ទៀតដើម្បីបង្កើតកាលានុវត្តភាពពាណិជ្ជកម្មនិងវិនិយោគរវាងស្ថាប័នទាំងពីរឱ្យកាន់តែល្អប្រសើរ ជាពិសេសការចុះអនុស្សារណៈយោគយល់គ្នា និងការកៀរគរវិនិយោគិនសក្តានុពលបន្ថែម ព្រមទាំងបន្តការពង្រីកកិច្ចសហប្រតិបត្តិការជាដៃគូគ្រប់ជ្រុងជ្រោយរវាងសមាគមឧកញ៉ាកម្ពុជា និងសភាពាណិជ្ជកម្មនិងឧស្សាហកម្មជប៉ុន។

គួររំលឹកផងដែរថាក្នុងឱកាសចូលរួមអមដំណើរសម្តេចធិបតីនាយករដ្ឋមន្ត្រីទៅប្រទេសជប៉ុនក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៣ អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា តំណាង អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមទាំងសមាជិកក្រុមប្រក្សាភិបាលសមាគម បានជួបពិភាក្សាធុរកិច្ចម្តងរួចមកហើយនៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ ទន្ទឹមនឹងនោះដែរ តំណាងសមាគមឧកញ៉ាកម្ពុជា ក៏បានអញ្ជើញភាគីជប៉ុនមកបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជាក្នុងពេលវេលាសមស្របណាមួយ។ ជាការឆ្លើយតប ភាគីជប៉ុនបានមកបំពេញទស្សនកិច្ចនៅកម្ពុជានៅដើមខែកុម្ភៈនេះ ដូច្នេះ សមាគមឧកញ៉ាកម្ពុជា ក៏បានរៀបចំទទួលស្វាគមន៍ និងអញ្ជើញ គណៈប្រតិភូគណៈកម្មាការមេគង្គ-ជប៉ុន នៃសភាពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុន ទទួលទានអាហារថ្ងៃត្រង់ ដើម្បីបន្តពិភាក្សាការងារធុរកិច្ច និងរឹតចំណងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ។











# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបំពេញបេសកកម្មនៅប្រទេសថៃ ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤

ក្នុងឱកាសបំពេញបេសកកម្មនៅក្នុងប្រទេសថៃ នារសៀលថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សាធុរកិច្ចជាមួយ ឯកឧត្តម ហ៊ុន សារឿន ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ នាស្ថានទូតកម្ពុជានៅក្នុងទីក្រុងបាងកក។ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានជម្រាបជូនឯកឧត្តមឯកអគ្គរាជទូតនូវការផ្តាំផ្ញើការសួរសុខទុក្ខ និងការគោរពជូនពរពីអ្នកឧកញ៉ាប្រធាន។

ក្នុងជំនួបនេះដែរអ្នកឧកញ៉ាហ៊ុនឡាក់បានជម្រាបជូនឯកឧត្តមឯកអគ្គរាជទូតអំពីសាវតាសមាគមចក្ខុវិស័យ និងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជា ជាពិសេសតួនាទីស្នូលដែលបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ **នស/រកត/១០២៣/២២៥០ ស្តីពីគោរមងារឧកញ៉ា** ព្រមទាំងបានបង្ហាញពីកិច្ចការ និងសមិទ្ធផលសំខាន់ៗដែលសមាគមបាននិងកំពុងអនុវត្តយ៉ាងសកម្មក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងភាពជាដៃគូមួយដ៏មានសក្តានុពលក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម និងការទាក់ទាញវិនិយោគិនមកកាន់ប្រទេសកម្ពុជា។ កិច្ចពិភាក្សាធុរកិច្ចនេះ នឹងបើកឱកាសឱ្យសមាជិកសមាគមទាំងអស់អាចស្វែងរកដៃគូអាជីវកម្ម ការផ្គូផ្គងពាណិជ្ជកម្ម និងការកៀរគរវិនិយោគិនបន្ថែមទៀតក្នុងវិស័យសក្តានុពលរបស់កម្ពុជាតាមរយៈការភ្ជាប់ទំនាក់ទំនង និងភាពជាដៃគូជាមួយវិនិយោគិនថៃ និងវិនិយោគិនផ្សេងៗដែលបាននិងកំពុងធ្វើអាជីវកម្មនៅក្នុងប្រទេសថៃនេះផ្ទាល់តែម្តងតាមរយៈការជួយសម្របសម្រួល និងសហការរៀបចំដោយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ។





ឯកឧត្តមហ៊ុន សារឿន បានកោតសរសើរពីសមិទ្ធផល និងកិច្ចខិតខំប្រឹងប្រែងនានាជាមួយរាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធក្រោមការដឹកនាំរបស់អ្នកឧកញ៉ា លី យ៉ុងផាត់ ដែលសមាគមសម្រេចបានក្នុងនាមជាស្ថាប័នតែមួយគត់ដែលតំណាងគោរមវន្តទាំងអស់នៅកម្ពុជាដែលមានចែងនៅក្នុងព្រះរាជក្រឹត្យខាងលើ។ឯកឧត្តមបានបន្តថាស្ថានទូតនឹងខិតខំឱ្យអស់ពីលទ្ធភាពនិងសមត្ថភាពដើម្បីផ្សព្វផ្សាយអំពីសក្តានុពលវិនិយោគនៅក្នុងប្រទេសកម្ពុជានិងសមាគមឧកញ៉ាកម្ពុជាជូនបណ្តាធុរជនថៃ និងស្ថានទូតនៃប្រទេសជាមិត្តជាពិសេសការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការ, វេទិកាធុរកិច្ច, ការផ្គូផ្គងអាជីវកម្ម និងកិច្ចសន្ទនាអាជីវកម្មនានាដែលជាផ្នែកមួយនៃការជួយជ្រោមជ្រែងដល់ការផ្គូផ្គងរវាងពាណិជ្ជករកម្ពុជាជាមួយដៃគូបរទេសនិងថៃដែលសុទ្ធសឹងតែជាពាណិជ្ជករមានសក្តានុពលដើម្បីជាគុណប្រយោជន៍សម្រាប់វិស័យសេដ្ឋកិច្ចកម្ពុជា ជាពិសេសគម្រោងក្នុងការអញ្ជើញធុរជនថៃទៅទស្សនកិច្ច និងស្វែងរឱកាសវិនិយោគនៅកម្ពុជា ពិសេសនៅខេត្តព្រះសីហនុនាពេលសមស្របណាមួយ។

លើសពីនេះ ឯកឧត្តម បានសង្កត់ធ្ងន់ថា តាមរយៈសមាគមឧកញ៉ាកម្ពុជា គឺជាច្រកមួយក្នុងការគៀរគរវិនិយោគិនពីកម្ពុជាមកវិនិយោគនៅថៃផងដែរនាពេលខាងមុខតាមរយៈកិច្ចសហប្រតិបត្តិការនិងការជួយសម្របសម្រួលដោយស្ថានទូតយើង ក្នុងភាពជាដៃគូផ្នែកឯកជនមួយដែលមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមអភិវឌ្ឍន៍ជាតិ និងការបង្កើតការងារជាដើម។ ជាកិច្ចបញ្ចប់ស្ថាប័នទាំងពីរតាំងចិត្តរួមគ្នាក្នុងការបន្តកិច្ចសហប្រតិបត្តិការ និងស្វែងរកកាលានុវត្តភាពបន្ថែមទៀតដល់ធុរកិច្ចជនទាំងសងខាង តាមរយៈការបង្កើតឱ្យមានយន្តការទំនាក់ទំនងដ៏មានប្រសិទ្ធភាពមួយរវាងស្ថាប័នទាំងពីរនាពេលសមស្រមណាមួយ។





នារសៀលថ្ងៃដដែលនោះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាធុរកិច្ចជាមួយលោកជំទាវ Orna Sagiv ឯកអគ្គរដ្ឋទូតអ៊ីស្រាអែលប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍នាស្ថានទូតនៅទីក្រុងបាងកក។

តាមរយៈកិច្ចពិភាក្សាធុរកិច្ចនេះ នឹងបើកឱកាសឱ្យសមាជិកសមាគមទាំងអស់អាចស្វែងរកដៃគូអាជីវកម្ម ការផ្គូផ្គងពាណិជ្ជកម្ម និងការគៀរគរវិនិយោគិនទៅតាមវិស័យរបស់ខ្លួន ជាពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម កសិ-ម្ហូបអាហារ ការកែច្នៃកសិផល ការគ្រប់គ្រងនិងប្រើប្រាស់ទឹក បច្ចេកវិទ្យាព័ត៌មាន និងធនធានសក្តានុពលវិស័យពាក់ព័ន្ធផ្សេងទៀតរបស់កម្ពុជាជាមួយវិនិយោគិនអ៊ីស្រាអែលតាមរយៈការជួយសម្របសម្រួលនិងសហការរៀបចំដោយស្ថានទូតអ៊ីស្រាអែលដោយផ្ទាល់នាពេលខាងមុខ។

លោកជំទាវ Orna Sagiv បានបង្ហាញពីសក្តានុពលក្នុងវិស័យកសិកម្ម កសិ-បច្ចេកវិទ្យា កសិ-នវានុវត្តន៍ ការគ្រប់គ្រងនិងប្រើប្រាស់ទឹក និងព័ត៌មាននិងបច្ចេកវិទ្យាព័ត៌មានដែលបាននិងកំពុងក្លាយជាវិស័យមួយដ៏លេចធ្លោរបស់អ៊ីស្រាអែលជូនដល់គណៈប្រតិភូ ជាពិសេសលោកជំទាវក៏ចង់បានដៃគូពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជាផងដែរក្នុងចំណោមសមាជិកសមាគមតាមវិស័យដូចបានបញ្ជាក់ខាងលើ។ ជាមួយគ្នានេះដែរ លោកជំទាវនឹងខិតខំឱ្យអស់ពីលទ្ធភាពនិងសមត្ថភាពដើម្បីផ្សព្វផ្សាយអំពីជាមួយសក្តានុពលវិនិយោគនៅកម្ពុជានិងសមាគមឧកញ៉ាកម្ពុជាជូនបណ្តាធុរជនអ៊ីស្រាអែល ជាពិសេសការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការ, វេទិកាធុរកិច្ច, ការផ្គូផ្គងអាជីវកម្ម និងកិច្ចសន្ទនាអាជីវកម្មនានាដែលជាផ្នែកមួយនៃការជួយជ្រោមជ្រែងដល់ការផ្គូផ្គងពាណិជ្ជកម្មរវាងកម្ពុជានិងអ៊ីស្រាអែលដើម្បីស្វែងរកកាលានុវត្តភាពនិងសក្តានុពលពាណិជ្ជកម្មអន្តរជាតិរវាងប្រទេសទាំងពីរ។លើសពីនេះលោកជំទាវបានសង្កត់ធ្ងន់ថាតាមរយៈសមាគមឧកញ៉ាកម្ពុជាគឺជាច្រកមួយដ៏សំខាន់ព្រោះសមាគមគឺជាបណ្តុំវិនិយោគិនដ៏ធំនិងពិពិធកម្មវិស័យនៅកម្ពុជា និងជាដៃគូដ៏មានសក្តានុពលជាមួយអ៊ីស្រាអែល តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយសម្របសម្រួលដោយស្ថានទូត ក្នុងភាពជាដៃគូពាណិជ្ជកម្ម។

ស្ថាប័នទាំងពីរមានមហិច្ឆិតារួមគ្នាក្នុងការបន្តកិច្ចសហប្រតិបត្តិការនិងស្វែងរកកលានុវត្តនិងស្វែងរកកាលានុវត្តភាពបន្ថែមទៀតដល់ធុរកិច្ចជនទាំងសងខាងតាមរយៈការបង្កើតឱ្យមានយន្តការទំនាក់ទំនងមានប្រសិទ្ធភាពមួយរវាង

ស្ថាប័នទាំងពីរនាពេលសមស្រមណាមួយជាពិសេសលោកជំទាវក៏នឹងស្នើឱ្យមានដំណើរបំពេញទស្សនកិច្ចឬបេសកកម្មធុរកិច្ចទៅវិញទៅមកក្នុងពេលណាមួយដែលអំណោយផល។

បន្ទាប់មកទៀតនារសៀលថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមវេទិកាការទូតសេដ្ឋកិច្ច ក្រោមប្រធានបទ៖ កម្ពុជាទំព័រថ្មី «ឱកាសធុរកិច្ច និងការវិនិយោគ» នៅទីតាំងអគារ CW Tower នៃទីក្រុងបាងកកដែលត្រូវបានរៀបចំឡើងដោយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃដឹកនាំដោយ ឯកឧត្តម ហ៊ុន សារឿន ឯកអគ្គរាជទូត និងសហការីមន្ត្រីស្ថានទូត។

វេទិកានេះមានភ្ញៀវកិត្តិយសចូលរួមសរុបប្រមាណ ២៣០រូបរួមមាន ឯកអគ្គរាជទូត/រដ្ឋទូត មន្ត្រីការទូត នៃស្ថានទូតបរទេសនៅទីក្រុងបាងកក តំណាងអង្គការអន្តរជាតិ តំណាងក្រសួងស្ថាប័នរដ្ឋ និងវិស័យឯកជននៅប្រទេសថៃ តំណាងសមាគមមិត្តភាពថៃ-កម្ពុជា និងតំណាងសមាគមឧកញ៉ាកម្ពុជាផងដែរ។

ជាមួយគ្នានេះ ប្រធានបទចំនួន ៤ ត្រូវបានជ្រើសរើសមកធ្វើបទឧទ្ទេសនាមជូនអង្គវេទិការួមមាន៖

- **ទី១៖** **«ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការ វិនិយោគផ្ទាល់ពីបរទេស»** ធ្វើបទឧទ្ទេសនាមដោយវាគ្មិនកិត្តិយស ឯកឧត្តមបណ្ឌិត ជាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ទី២៖** **«ឱកាសធុរកិច្ចនៅកម្ពុជា»** ធ្វើបទឧទ្ទេសនាមដោយវាគ្មិនកិត្តិយសឯកឧត្តមសុខ សុភ័ក្ត្រ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។
- **ទី៣៖** **«ធុរកិច្ច និងការវិនិយោគ៖ ច្បាប់ស្តីពីការវិនិយោគ(ថ្មី) និងទិដ្ឋភាពទូទៅនៃសក្តានុពលឧស្សាហកម្ម និងបរិយាកាសវិនិយោគអំណោយផលសម្រាប់ FDI ហេតុអ្វីបានជាចាំបាច់ត្រូវវិនិយោគនៅកម្ពុជា?»** ធ្វើបទឧទ្ទេសនាមដោយវាគ្មិនកិត្តិយសឯកឧត្តមសួន សុផល អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា
- **ទី៤៖** **«នីតិវិធីនិងដំណើរការពន្ធដារ៖ ទិដ្ឋភាពច្បាប់របស់កម្ពុជាលើនីតិវិធីនៃការវិនិយោគ និងពន្ធ ការផ្ទេរដើមទុនលក្ខខណ្ឌនិងទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀងស្តីពីពន្ធត្រួតគ្នា(DTA)»** ធ្វើបទឧទ្ទេសនាមដោយវាគ្មិនកិត្តិយសលោកជំទាវ ប៊ុន នារី អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ។

វេទិកានេះត្រូវបានស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ រៀបចំឡើងដើម្បីជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងទៀតដើម្បីជំរុញផ្សព្វផ្សាយអំពីសក្តានុពលសេដ្ឋកិច្ចទេសចរណ៍និងវប្បធម៌កម្ពុជា ឱ្យសុះសាយគ្រប់ទិសទីក្នុងសកលលោក ក្នុងគោលដៅទាក់ទាញទេសចរបរទេស និងទុនវិនិយោគផ្ទាល់ពីបរទេសមកកាន់កម្ពុជាឱ្យកាន់តែមានសន្ទុះកើនឡើងជាបន្តបន្ទាប់សំដៅលើកកម្ពស់កិត្យានុភាពជាតិខ្មែរនិងសម្រេចចក្ខុវិស័យកម្ពុជា ក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។








# កម្មវិធីសប្បុរសធម៌នៅសាលាអនុវិទ្យាល័យស្ទឹងជ្រៅ ក្នុងភូមិស្ទឹងជ្រៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល

អនុលោមតាមចក្ខុវិស័យនិងបេសកកម្មមនុស្សធម៌ដែលត្រូវបានចារឹកនៅក្នុងលក្ខន្តិកៈរបស់ខ្លួន នាថ្ងៃអាទិត្យ ៩កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំអ្នកឧកញ៉ា និងឧកញ៉ា ចំនួន ២៣រូប ជាថ្នាក់ដឹកនា និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាដើម្បីចុះសំណេះសំណាលនិងនាំយកនូវអំណោយជាថវិកាក៏ដូចជាសម្ភារសិក្សាប្រគល់ជូនសាលាអនុវិទ្យាល័យស្ទឹងជ្រៅដែលស្ថិតនៅភូមិស្ទឹងជ្រៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ដោយរួមមានថវិកាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអនុវិទ្យាល័យនេះរួមមាន ក្រាលការ៉ូឡាប្រមាណ ១១៥០ម៉ែត្រការ៉េ ក៏ដូចជាខ្សាច់ ស៊ីម៉ង់ត៍ និងព្រំការ៉ូឡាជាដើម ព្រមទាំងនាំយកនូវអំណោយជាឯកសណ្ឋានសិស្ស សម្ភារសិក្សា កង់ កាបូប និងសម្លៀកបំពាក់ដល់លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតាអាណាព្យាបាលសិស្ស ដែលមានចំនួនសរុបប្រមាណ ២៦០នាក់ ព្រមទាំងសៀវភៅចំនួន ៣១៥ក្បាលសម្រាប់តម្កល់ក្នុងបណ្ណាល័យ និងផ្ទើចំនួន ៦ ។ ចំពោះលោកគ្រូ អ្នកគ្រូ និងគណៈទ្រទ្រង់សាលាសរុបចំនួន ៣០រូបទទួលបានកញ្ចប់ជាសម្លៀកបំពាក់ និងថវិកាក្នុងម្នាក់ៗចំនួន ១លានរៀល។ អាជ្ញាធរដែនដីនិងអាណាព្យាបាលសិស្សមានចំនួន២៨រូបទទួលបានញ្ចប់ជាសម្លៀកបំពាក់និងថវិកាក្នុងម្នាក់ៗចំនួន ៥ម៉ឺនរៀល។ ចំណែកសិស្សានុសិស្សចំនួន ២០០នាក់ទទួលបានកាបូបម្នាក់១ ឯកសណ្ឋានសិស្សម្នាក់ ១ឈុត, ស្បែកជើងម្នាក់ ១គូ, សម្លៀកបំពាក់ ២ឈុត, សម្ភារសិក្សាមានសៀវភៅ ប៊ិច ខ្មៅដៃ ទឹកលុប ហាយឡាយ ជាដើម ព្រមទាំងថវិកាម្នាក់ៗទទួលបាន ៥ម៉ឺនរៀល។ ដែលសរុបជាថវិកាចំនួន ៥៦.១៣៤ដុល្លារអាម៉េរិច។











សូមបញ្ជាក់ថាជារៀងរាល់ឆ្នាំសាលាអនុវិទ្យាល័យស្ទឹងជ្រៅតែងតែជួបប្រទះនូវការលំបាកជាច្រើនដូចជាការលិចលង់នារដូវវស្សា ការខ្វះខាតសៀវភៅអានក្នុងបណ្ណាល័យ តម្រូវការជំនួយគាំទ្រលើមធ្យោបាយធ្វើដំណើររបស់សិស្សក្រីក្រ និងសម្ភារៈសិក្សាជាដើម។ ហេតុនេះ ហើយទើប និងគណៈគ្រប់គ្រងបានស្វែងរកជំនួយផ្សេងតាមរយៈឯកឧត្តម ប៉ែន បូណា ជាមួយនឹងក្តីសង្ឃឹមថានឹងអាចដោះស្រាយបញ្ហាប្រឈមទាំងនេះ។

ជាការឆ្លើយតប អ្នកឧកញ៉ា លី យ៉ុងផាត់ បានទទួលយកសំណើទាំងស្រុងនិងបានសម្រេចចូលរួមឧបត្ថម្ភជាថវិកាពីសមាគមឧកញ៉ាកម្ពុជារួមជាមួយសម្ភារជាច្រើនមុខទៀតដែលទទួលបានពីអ្នកឧកញ៉ានិងឧកញ៉ាជាថ្នាក់ដឹកនាំនិងសមាជិករបស់សមាគមឧកញ៉ាកម្ពុជា។អ្នកឧកញ៉ា លី យ៉ុងផាត់ បានលើកឡើងថាអ្នកឧកញ៉ាមានក្តីសង្ឃឹមយ៉ាងមុតមាំថា អំណោយដែលសមាគមឧកញ៉ាកម្ពុជា ផ្តល់ជូននៅពេលនេះ នឹងអាចប្រើប្រាស់ចំគោលដៅពិសេសដល់ការរៀបចំសោភ័ណភាពនៅក្នុងសាលានិងបានបំពេញតម្រូវការរបស់សិស្សានុសិស្សទាំងអស់ដែលកំពុងសិក្សានៅក្នុងសាលាអនុវិទ្យាល័យស្ទឹងជ្រៅនេះតែម្តងដូចដែលសុភាសិតខ្មែរបានពោលថា៖«អ្នកមានរក្សាខ្សត់ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញារក្សាខ្លៅដូចសំពៅពឹងសំប៉ាន។»















# កម្មវិធីសប្បុរសធម៌នៅខេត្តកំពង់ស្ពឺ ដើម្បីនាំយកអំណោយជូនមណ្ឌលកុមារកំព្រាចំនួន៤កន្លែង

នាថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានបន្តដឹកនាំ អ្នកឧកញ៉ា និង ឧកញ៉ា ចំនួន២៥រូបដែលជាថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាដើម្បីចុះសំណេះសំណាល និងប្រគល់ថវិកាជូនមណ្ឌលកុមារកំព្រាចំនួន ៤ដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ស្ពឺរួមមាន៖ មណ្ឌលកុមារកំព្រាខេត្តកំពង់ស្ពឺ, មណ្ឌលកុមារកំព្រាព្រៃជុំ, សហគមន៍ផ្ទះជាក្រុមរបស់យើង និងអង្គការកុមារក្តីសង្ឃឹមថ្មី។ ក្នុងកម្មវិធីនេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមវីសំណាងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺព្រមទាំងថ្នាក់ដឹកនាំនិងតំណាងមន្ទីរក៏ដូចជាស្ថាប័នមួយចំនួននៅក្នុងខេត្តកំពង់ស្ពឺផងដែរ។

អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានថ្លែងថា ដោយមើលឃើញពីការខ្វះខាត និងតម្រូវការជាក់ស្តែងរបស់មណ្ឌលកុមារកំព្រាទាំងបួននេះសមាគមឧកញ៉ាកម្ពុជាបានកៀរគរសប្បុរសជននានាដែលជាសមាជិករបស់សមាគមដើម្បីជួយដល់កុមារកំព្រា និងអ្នកមើលថែសរុបចំនួន ២៣៤នាក់ដោយអំណោយទាំងនេះមានដូចជា គ្រឿងឧបភោគ បរិភោគប្រចាំថ្ងៃ និងសម្លៀកបំពាក់ជាដើម។











សូមជម្រាបថា នៅក្នុងសកម្មភាពសប្បុរសធម៌នេះដែរមានសប្បុរសជនជា អ្នកឧកញ៉ា និងឧកញ៉ាចំនួន ៧ រូបបានចូលរួមឧបត្ថម្ភបន្ថែមទៀតនូវថវិកា និងសម្ភារជាច្រើនដូចជា៖

១- អ្នកឧកញ៉ា លី យ៉ុងផាត់ ថវិកាចំនួន២០លានរៀល រួមនឹងម៉ាស១កេសធំ និងអាវយឺតចំនួន ៣៧០អាវ

២- អ្នកឧកញ៉ា លាង យុន ទឹកបរិសុទ្ធកម្ពុជា៥០០កេស និងភេសជ្ជៈ IZE ៥០០ យួរ

៣- អ្នកឧកញ៉ា លី សាំងឡេង ថវិកាចំនួន ៤លានរៀល

៤- អ្នកឧកញ៉ា តុល លន ថវិកាចំនួន ៤លានរៀល

៥- ឧកញ៉ា លឹម ជា សម្លៀកបំពាក់ចំនួន ២៤៥០ ឈុត

៦- ជំទាវឧកញ៉ា គី ម៉ានេ និងជំទាវឧកញ៉ា គួន ធីតា ថវិកាចំនួន៤លានរៀល

ចំពោះមណ្ឌលកុមារកំព្រាកំពង់ស្ពឺទទួលបានអង្ករ ២តោន, ទឹកត្រី ៥០យួរ, ទឹកស៊ីអ៊ីវ ៥០យួរ, ត្រីខ ១០កេស ,សាប៊ូម្សៅ ១០០គីឡូក្រាម, ស្ករស ១០០គីឡូក្រាម, ស្ករត្នោត ២០គីឡូក្រាម, ប្រហុក ២០គីឡូក្រាម, ប៊ីចេង ២០គីឡូក្រាម, ខ្ទឹមស ១៥គីឡូក្រាម, ខ្ទឹមក្រហម ១០គីឡូក្រាម, ប្រេងឆាចំណុះ ៦លីត្រ ១០កេស, ប្រេងខ្យងចំណុះ ៦០០មីលីលីត្រ ១០កេស, ម្សៅស៊ុបខ្នចំណុះ ៨០០ក្រាម ១០កញ្ចប់ផងដែរ និងថវិកាចំនួន ៧លាន ៥សែនរៀល។ ចំពោះមណ្ឌល ៣ផ្សេងទៀតទទួលបាន អង្ករ ២តោន, មី ១០កេស, អំបិល ១០គីឡូក្រាម, មី ១០កេស, ត្រីខ ១០កេសធំ, ប៊ីចេង ១០កេស, សាប៊ូម្សៅ ១០០គីឡូក្រាមផងដែរ និងថវិកាដោយមួយមណ្ឌលទទួលបានចំនួន ៧លាន ៥សែនរៀលផងដែរ។ សម្រាប់អ្នកចូលរួមចំនួន ២៣៤នាក់ទទួលបានកាបូប សម្លៀកបំពាក់ និងថវិកាចំនួន ៥ម៉ឺនរៀលក្នុងម្នាក់។ សរុបជាថវិកាចំនួន ៤០,៣៤៧ដុល្លារអាម៉េរិក។







# ពិធីប្រកាសជាផ្លូវការ និងកិច្ចប្រជុំលើកដំបូងនៃក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា (ICJBC)

សមាគមឧកញ៉ាកម្ពុជា (COA) និងសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា (FICCI) បានសម្រេចបង្កើតជាផ្លូវការក្រុមប្រឹក្សាធុរកិច្ចរួមគ្នារវាងឥណ្ឌា-កម្ពុជា ឬ the India-Cambodia Joint Business Council (ICJBC) តាមរយៈពិធីសម្ពោធនាថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តម ទិត រិទ្ធីពល អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិង លោក Rajesh Kumar Singh លេខាធិការនៃនាយកដ្ឋានជំរុញឧស្សាហកម្ម និងពាណិជ្ជកម្មផ្ទៃក្នុងប្រទេស (DPIIT) និងជាតំណាងក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា។

ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងក្នុងគោលដៅជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសឥណ្ឌា-កម្ពុជា តាមរយៈកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការរវាង វិស័យឯកជននៃប្រទេសទាំងពីរដោយមានគោលបំណងបង្កើតឡើងនូវយន្តការពិគ្រោះយោបល់ទ្វេភាគីដើម្បីឱ្យបណ្តាធុរជនដ៏មានសក្តានុពលនៃប្រទេសទាំងពីរអាចជជែកពិភាក្សាព្រមទាំងស្នើនូវដំណោះស្រាយផ្សេងៗដើម្បីបង្កើនសកម្មភាពពាណិជ្ជកម្ម ការវិនិយោគ និងកិច្ចសហប្រតិបត្តិការលើវិស័យនានារួមទាំងការលើកកម្ពស់និងការសម្របសម្រួលពាណិជ្ជកម្មក៏ដូចជាការផ្គូផ្គងដៃគូក្នុងវិស័យឧស្សាហកម្ម នវានុវត្តន៍ និងសហគ្រិនភាព ព្រមទាំងកិច្ចសម្របសម្រួលលើបម្លាស់ប្តូរបច្ចេកវិទ្យារវាងភាគីទាំងពីរ ជាពិសេសផ្តោតទៅលើវិស័យអាទិភាពរួមមាន៖ ទេសចរណ៍, ផលិតកម្មកែច្នៃម្ហូបអាហារ, សុខាភិបាល និងឱសថ, វិស័យអប់រំ,ព័ត៌មានវិទ្យា, កសិកម្ម, សំណង់និងហេដ្ឋារចនាសម្ព័ន្ធ,ព័ត៌មានវិទ្យា, ឧស្សាហកម្មយានយន្ត និងវិស័យពាក់ព័ន្ធជាច្រើនទៀត។









សូមជម្រាបផងដែរថា ក្រុមប្រឹក្សាធុរកិច្ចរួមគ្នានេះមាននាយកដ្ឋានជំរុញឧស្សាហកម្ម និងពាណិជ្ជកម្មផ្ទៃក្នុងប្រទេស (DPIIT) ជាលេខាធិការដ្ឋានសម្រាប់ភាគីឥណ្ឌា ចំណែកសមាគមឧកញ៉ាកម្ពុជា (COA) នឹងបំពេញតួនាទីជាលេខាធិការដ្ឋានសម្រាប់ភាគីកម្ពុជា។នៅក្នុងពិធីសម្ពោធជាផ្លូវការនេះក៏មានការផ្គូផ្គងពាណិជ្ជកម្មរវាងភាគីទាំងពីរ ដោយរួមមានក្រុមធុរជនរបស់កម្ពុជាជាមួយនឹងក្រុមពាណិជ្ជកររបស់ឥណ្ឌាដែលសុទ្ធតែជាក្រុមហ៊ុនធំៗដែលកំពុងវិនិយោគលើវិស័យសំខាន់ៗដូចជា៖ ការអភិវឌ្ឍន៍ជំនាញ, ការរុករក និងជីកយករ៉ែ, សុខាភិបាល, ផលិតកម្មកែច្នៃម្ហូបអាហារ, វិស័យសំណង់, ការស្រាវជ្រាវអប់រំ និងអចលនទ្រព្យជាដើម។

នៅក្នុងពិធីនេះដែរ សហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌា និងសមាគមឧកញ៉ាកម្ពុជា បានចុះហត្ថលេខារួមគ្នាលើឯកសារយោងសំខាន់ៗដើម្បីបង្កើតនូវយន្តការនៃកិច្ចប្រជុំប្រជុំឆ្នាំរបស់ក្រុមប្រឹក្សាធុរកិច្ចរួមនេះ ដោយនឹងត្រូវធ្វើឡើងនៅក្នុងប្រទេសឥណ្ឌាឬនៅក្នុងប្រទេសកម្ពុជាពោលគឺអាស្រ័យលើការសម្រេចរវាងភាគីទាំងពីរ។ សូមបញ្ជាក់ថា ចំនុចសំខាន់ៗរបស់ក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា រួមមានដូចជា៖

- ក្រុមប្រឹក្សានេះនឹងដឹកនាំរួមគ្នាដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃវិស័យឧស្សាហកម្មនៃប្រទេសនីមួយៗ
- ការបញ្ចូលនូវសមាជិកមកពីពហុវិស័យដែលតំណាងឱ្យក្រុមហ៊ុនឯកជនដែលមានចំណាប់អារម្មណ៍លើការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌា និងកម្ពុជា
- យន្តការផ្លាស់ប្តូរជាប្រចាំនូវព័ត៌មាន និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម, ការវិនិយោគ និងនិន្នាការទីផ្សាររបស់ប្រទេសទាំងពីរ
- ការផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលនៃប្រទេសទាំងពីរដើម្បីកែលម្អបរិយាកាសធុរកិច្ចវិនិយោគនិងការបំពេញអាជីវកម្មនានា។

អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានលើកឡើងថា៖ "ពិធីសម្ពោធជាផ្លូវការក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជានេះគឺជាបោះជំហានចូលទៅកាន់ទំព័រថ្មីនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេស ទាំងពីរ នេះជាគឺជាវេទិកាមួយដែលនឹងអនុញ្ញាតឱ្យយើងកំណត់បាននូវបញ្ហាប្រឈម និងការប្រកួតប្រជែងនានាដើម្បីបង្កើតនូវកាលានុវត្តភាពថ្មីៗសម្រាប់បំពេញផលប្រយោជន៍សេដ្ឋកិច្ចជាតិទៅវិញទៅមក។"

សូមបញ្ជាក់ថាការបង្កើតជាផ្លូវការនៃក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា នេះនឹងទាក់ទាញបណ្តាធុរជននៅក្នុងប្រទេសទាំងពីរកាន់តែខ្លាំងដើម្បីចូលរួមក្នុងការត្រួសត្រាយអនាគតដ៏ត្រះត្រចង់នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឥណ្ឌា និងកម្ពុជាឆ្ពោះទៅរកការរីកចម្រើន និងវិបុលភាពរួមគ្នានៃប្រជាជាតិទាំងពីរ។









# កិច្ចប្រជុំធុរកិច្ចរវាងគណៈប្រតិភូសមាគមឧកញ៉ា និងឯកឧត្តមឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅសាធារណរដ្ឋឥណ្ឌា

នាព្រឹកថ្ងៃសៅរ៍ ១៥កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាជួបសម្តែងការគួរសម និងពិភាក្សាកិច្ចការធុរកិច្ចជាមួយ ឯកឧត្តម កុយ គួង ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសឥណ្ឌា នៅទីក្រុងញូវដេលី។ ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានជម្រាបជូន ឯកឧត្តមឯកអគ្គរាជទូតនូវការផ្តាំផ្ញើការសួរសុខទុក្ខ និងការគោរពជូនពរពីអ្នកឧកញ៉ាប្រធានផងដែរ។

ឯកឧត្តម  កុយ គួង បានកោតសរសើរពីសមិទ្ធផល និងកិច្ចខិតខំប្រឹងប្រែងនានាជាមួយរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធក្រោមការដឹកនាំរបស់អ្នកឧកញ៉ាលីយ៉ុងផាត់។ឯកឧត្តមបានបន្តថាស្ថានទូតនឹងខិតខំឱ្យអស់ពីលទ្ធភាពដើម្បីផ្សព្វផ្សាយអំពីសក្តានុពលវិនិយោគនៅក្នុងប្រទេសកម្ពុជា និងសមាគមឧកញ៉ាកម្ពុជាជូនបណ្តាធុរជនឥណ្ឌា ជាពិសេសការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការ, ការផ្គូផ្គងអាជីវកម្ម និងកិច្ចសន្ទនាជាមួយដៃគូឥណ្ឌា ដែលសុទ្ធសឹងតែជាពាណិជ្ជករមានសក្តានុពលដើម្បីជាគុណប្រយោជន៍ជួយអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ។ លើសពីនេះ ឯកឧត្តមបានសង្កត់ធ្ងន់ថា តាមរយៈសមាគមឧកញ៉ាកម្ពុជាគឺជាច្រកមួយក្នុងការកៀរគរវិនិយោគិនផងដែរនាពេលខាងមុខតាមរយៈកិច្ចសហប្រតិបត្តិការនិងការជួយសម្របសម្រួលដោយស្ថានទូតក្នុងភាពជាដៃគូផ្នែកឯកជនមួយដែលមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចូលរួមអភិវឌ្ឍជាតិ និងការបង្កើតការងារជាដើម។

កិច្ចពិភាក្សាធុរកិច្ចនេះនឹងបើកឱកាសឱ្យសមាជិកសមាគមទាំងអស់ដែលកំពុងប្រកបជំនួញលើពហុវិស័យនៅកម្ពុជាអាចស្វែងរកដៃគូអាជីវកម្ម ការផ្គូផ្គងពាណិជ្ជកម្ម និងការកៀរគរវិនិយោគិនបន្ថែមទៀតក្នុងវិស័យសក្តានុពលរបស់កម្ពុជាតាមរយៈការភ្ជាប់ទំនាក់ទំនងនិងភាពជាដៃគូជាមួយវិនិយោគិនឥណ្ឌាដោយមានការជួយសម្របសម្រួលពីស្ថានទូតកម្ពុជាប្រចាំប្រទេសឥណ្ឌាផងដែរខណៈដែលឥណ្ឌាគឺជាប្រទេសដែលមានសក្តានុពលធំមានប្រជាជនច្រើន និងមានទំហំសេដ្ឋកិច្ចលំដាប់លេខ៣នៅលើពិភពលោកចំណែកឯជញ្ជីងពាណិជ្ជកម្មរវាងកម្ពុជានិងឥណ្ឌាក៏មានការកើនឡើងគួរឱ្យកត់សម្គាល់។







# កិច្ចប្រជុំធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជាជាមួយឯកឧត្តមឧត្តមសេនីយ៍ Jim L. Jones នាយកប្រតិបត្តិនៃក្រុមហ៊ុន Jones Group International

នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា តំណាង អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាប្រជុំទ្វេភាគីដើម្បីពិភាក្សាកិច្ចការធុរកិច្ចជាមួយឯកឧត្តមឧត្តមសេនីយ៍ ជេមស៍ ចូនស៍ (General James L. Jones) នាយកប្រតិបត្តិនៃក្រុមហ៊ុន Jones Group International នៅសណ្ឋាគារ Hyatt Regency ខណៈដែលឯកឧត្តមបានដឹកនាំក្រុមការងារជំនាញលើការងារផ្តល់ប្រឹក្សាយោបល់មួយក្រុមមកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងគោលបំណងលើកកម្ពស់ទំនាក់ទំនងការវិនិយោគនិងពាណិជ្ជកម្មរវាងកម្ពុជានិងអាម៉េរិកព្រមទាំងសិក្សាអំពីសក្តានុពលសេដ្ឋកិច្ចនិងបរិយាកាសវិនិយោគតាមរយៈជំនួបជាបន្តបន្ទាប់ជាមួយថ្នាក់ដឹកនាំរាជរដ្ឋាភិបាលក៏ដូចជាតំណាងសមាគមឧកញ៉ាកម្ពុជានិងតំណាងវិស័យឯកជនដទៃទៀតផងដែរ ជាពិសេសការពិភាក្សាទៅលើការបង្កើតយន្តការដើម្បីរៀបចំឱ្យមានជំនួបធុរកិច្ចរវាងធុរជនអាម៉េរិក និងកម្ពុជា។

ក្នុងឱកាសនោះអ្នកឧកញ៉ាសៀប្ញទ្ធីអនុប្រធានសមាគមឧកញ៉ាកម្ពុជាបានជម្រាបជូនឯកឧត្តមឧត្តមសេនីយ៍នូវសារតាព្រមជាមួយនឹងចក្ខុវិស័យនិងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជាដោយបានបង្ហាញពីកិច្ចការនិងសមិទ្ធផលសំខាន់ៗដែលសមាគមបាននិងកំពុងអនុវត្តយ៉ាងសកម្មក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងភាពជាដៃគូមួយដ៏មានសក្តានុពល ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម និងការទាក់ទាញវិនិយោគិនមកកាន់ប្រទេសកម្ពុជាជាមួយគ្នានេះផងដែរ អ្នកឧកញ៉ា ក៏បានបង្ហាញនូវសុទិដ្ឋិនិយមថា កិច្ចប្រជុំនេះនឹងនាំឱ្យមានការបើកផ្លូវ និងការសន្ទនាសម្រាប់ការភ្ជាប់ទំនាក់ទំនងការទូតសេដ្ឋកិច្ចរវាងធុរជនដែលជាសមាជិកសមាគមឧកញ៉ាកម្ពុជានិងស្ថាប័នដទៃទៀតជាមួយនឹងធុរជនអាម៉េរិក។ ទន្ទឹមនឹងនេះដែរ សមាគមឧកញ៉ាកម្ពុជាបានស្នើសុំឱ្យមានការពិភាក្សាបន្ថែមទៀតដើម្បីភ្ជាប់ទំនាក់ទំនងរវាងវិស័យឯកជននៃប្រទេសទាំងពីរដើម្បីបង្កើតឱ្យមានវេទិកាផ្គូផ្គងពាណិជ្ជកម្មនាពេលខាងមុខ។














នារសៀលថ្ងៃដដែលនោះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដឹកនាំដោយ អ្នកឧកញ៉ា សៀ ឬទ្ធី បានចូលរួមកិច្ចពិភាក្សាដើម្បីជំរុញកំណើនពាណិជ្ជកម្ម និងការវិនិយោគរវាងកម្ពុជា និងសហរដ្ឋអាមេរិក នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឯកឧត្តមឧត្តមសេនីយ៍ Jim Jones នាយកប្រតិបត្តិនៃក្រុមហ៊ុន Jones Group International ជាសហប្រធានក្នុងការរួមគ្នារៀបចំកិច្ចប្រជុំនេះឡើង។កិច្ចប្រជុំនេះមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានាទាំងរដ្ឋនិងឯកជនក្នុងនោះក៏មានសមាគមឧកញ៉ាកម្ពុជាផងដែរដើម្បីពិភាក្សាលើទស្សនវិស័យរួមនិងគោលដៅជាយុទ្ធសាស្ត្រនានាក្នុងការជំរុញកំណើនពាណិជ្ជកម្មនិងការវិនិយោគរវាងកម្ពុជានិងសហរដ្ឋអាម៉េរិកឱ្យបានកាន់តែប្រសើរថែមមួយកម្រិតទៀត។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីសហប្រធានអង្គប្រជុំ បានលើកឡើងនូវគោលដៅជាយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគី ដូចជាការត្រួសត្រាយកិច្ចសហប្រតិបត្តិការថ្មីៗ និងការពង្រីកឱ្យបានកាន់តែប្រសើរនូវពាណិជ្ជកម្ម និងការវិនិយោគ រវាងកម្ពុជា និងសហរដ្ឋអាម៉េរិក ដែលជាគោលដៅជាយុទ្ធសាស្ត្រមួយក្នុងការផ្តួចផ្តើមនូវការបង្កើនកិច្ចសម្របសម្រួលពាណិជ្ជកម្មឱ្យរលូនរួមមានការបង្កភាពងាយស្រួលលើនីតិវិធីគយកាត់បន្ថយរបាំងពាណិជ្ជកម្ម និងបទប្បញ្ញត្តិរដ្ឋបាលជាដើម។

អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា បានបង្ហាញនូវសុទិដ្ឋិនិយមថា កិច្ចប្រជុំនេះនឹងនាំឱ្យមានការបើកផ្លូវនិងការសន្ទានាធុរកិច្ចសម្រាប់ការភ្ជាប់ទំនាក់ទំនងការទូតសេដ្ឋកិច្ចរវាងធុរជនកម្ពុជា និងអាម៉េរិកក្នុងវិស័យផ្សេងៗក្នុពេលសមស្របណាមួយនាពេលខាងមុខ។ទន្ទឹមនឹងនេះដែរអ្នកឧកញ៉ាបានស្នើសុំឱ្យមានការពិភាក្សាបន្ថែមទៀតដើម្បីជំរុញការភ្ជាប់ទំនាក់ទំនងនេះ ដែលនឹងឈានទៅបង្កើតឱ្យមានវេទិកាផ្គូផ្គងពាណិជ្ជកម្មណាមួយ។

ជាការឆ្លើយតបនៅក្នុងជំនួបនេះឯកឧត្តមឧត្តមសេនីយ៍បានលើកឡើងពីការត្រៀមខ្លួនរួចជាស្រេចដើម្បីជួយជំរុញឱ្យមានការកើនឡើងនូវពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរ ស្របពេលនេះដែរ ឯកឧត្តមឧត្តមសេនីយ៍ ជឿជាក់ថាតាមរយៈពាណិជ្ជកម្ម និងការវិនិយោគ នឹងជំរុញឱ្យទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងសហរដ្ឋអាមេរិក កាន់តែល្អកើនឡើងមួយកម្រិតទៀត។

# ថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមពិធីផ្សព្វផ្សាយ “ការសាងសង់សួនតេជោសន្តិភាព”

នារសៀលថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ សមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន២១រូបបានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយ«**ការសាងសង់សួនតេជោសន្តិភាព**» នៅទីស្តីការក្រសួងការពារជាតិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ និងនាយទាហានជាច្រើនរូបទៀត។

សូមបញ្ជាក់ថាសួនតេជោសន្តិភាពមានការរៀបចំឡើងទៅតាមគំនិតផ្តួចផ្តើមនិងដឹកនាំផ្ទាល់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានរៀបរាប់អំពីដំណើរការ នៃការអនុវត្តនយោបាយឈ្នះឈ្នះ តាំងបង្ហាញជាតឹកតាងភូមិសាស្ត្រមួយចំនួនដែលមានលក្ខណៈស៊ីគ្នាតាមភាពជាក់ស្តែងនៃប្រវត្តិកាលនៃការអនុវត្តនយោបាយឈ្នះឈ្នះ របស់ **សម្តេចតេជោ ហ៊ុន សែន**។

យោងតាមរបាយការណ៍របស់នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះឈ្នះ បានថ្លែងថា ក្រោយការរៀបចំសួនប្រវត្តិកាលស្ថាបត្យកម្មវិមានឈ្នះឈ្នះនេះរួចហើយ ការតាមដាន ត្រួតពិនិត្យ និងសម្រេចលើអត្ថន័យដ៏មានសារៈសំខាន់នេះសួនប្រវត្តិកាលក៏បានធ្វើការកែសម្រួលក្នុងដំណាក់កាលទី៣ដោយផ្សារភ្ជាប់ជាមួយនឹងរូបភាពសួនតេជោសន្តិភាព ដើម្បីរៀបចំឱ្យទៅជាទីតាំងមួយដែលរក្សានូវទម្រង់ស្ថាបត្យកម្ម រួមបញ្ចូលជាមួយនឹងសួនតេជោសន្តិភាព។

នាយឧត្តមសេនីយ៍បានបញ្ជាក់ថាដោយមើលឃើញអំពីសារៈសំខាន់នេះសម្តេចពិជ័យសេនាទៀបាញ់បានឈានបន្តមួយជំហានទៀតក្នុងការកែសម្រួលបញ្ចូលគ្នារវាងស្ថាបត្យកម្មនៃសួនប្រវត្តិកាលស្ថាបត្យកម្មវិមានឈ្នះឈ្នះ និងសួនតេជោសន្តិភាពប្រែក្លាយទៅ«**សួនតេជោសន្តិភាព**»ដែលបង្ហាញអំពីវិមានឈ្នះឈ្នះនិងបង្ហាញអំពីភូមិសាស្ត្រដែលដំណើរការនយោបាយឈ្នះឈ្នះខ្ទាតតូចផងដែរ។ការរៀបចំនេះក៏ទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់និងដំណើរការព្រមទាំងរៀបចំលក្ខណៈវិនិច្ឆ័យ ដើម្បីជាស្ថាបត្យកម្មថ្មីមួយ ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រសម្រាប់ការកសាងជាបន្តទៀតនូវហេដ្ឋរចនា សម្ព័ន្ធជាតឹកតាងនៃសន្តិភាពជាគោល និងការអនុវត្តប្រកបដោយជោគជ័យនូវនយោបាយឈ្នះឈ្នះ របស់សម្តេចតេជោ និងជាមរតកសម្រាប់បន្តវេនដោយសម្តេចធិបតី។





# ពិធីបុណ្យផ្ការស្ទីសាមគ្គីជាតិដើម្បីកសាងព្រះពុទ្ធបដិមាកម្ពស់១០៨ ម៉ែត្រ និងពិធីរាប់បាត្រព្រះសង្ឃ ១,០០០ អង្គនៅលើភ្នំបូកគោ

នាព្រឹកថ្ងៃអាទិត្យ ៨រោច ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ាទី ពិសិដ្ឋ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយឧកញ៉ា លាង ហ៊ី ឧកញ៉ា សុខផេង ឧកញ៉ា ស៊ុយ ហេង និងឧកញ៉ា សាយ សុភ័ត្រា បាននាំយកបច្ច័យដែលបានពីការចូលរួមចាប់មគ្គផលរបស់ថ្នាក់ដឹកនាំនិងសមាជិកសមាគមឧកញ៉ាកម្ពុជាប្រគល់ជូនអ្នកឧកញ៉ា សុខ គង់ ទីប្រឹក្សាជាន់ខ្ពស់នៃសមាគមឧកញ៉ាកម្ពុជាដើម្បីចូលរួមពិធីបុណ្យផ្ការស្ទីសាមគ្គីជាតិដើម្បីកសាងព្រះពុទ្ធបដិមាកម្ពស់១០៨ ម៉ែត្រ និងពិធីរាប់បាត្រព្រះសង្ឃ១,០០០ អង្គនៅលើភ្នំបូកគោដោយតាមរយៈការផ្សព្វផ្សាយរបស់សមាគមឧកញ៉ាកម្ពុជា មានសប្បុរសជនចំនួន៥៦រូបបានចាប់មគ្គផលក្នុងកម្មវិធីបុណ្យនេះដែលទទួលបានបច្ច័យជាប្រាក់រៀលចំនួន៧៨,០០០,០០០រៀល និងប្រាក់ដុល្លារចំនួន ៦,៧៥០ ដុល្លារអាម៉េរិក។

សូមបញ្ជាក់ថា គម្រោង សាងសង់ព្រះពុទ្ធបដិមាកម្ពស់ ១០៨ ម៉ែត្រ នៅលើខ្នងភ្នំ បូកគោ ស្ថិតនៅក្នុងឧទ្យានជាតិ ព្រះមុនីវង្ស **«បូកគោ»** នេះជាគំនិតផ្តួចផ្តើមរបស់អ្នកឧកញ៉ា សុខ គង់ ដែលមានចក្ខុវិស័យ និងសទ្ធាជ្រះថ្លាយ៉ាងមុតមាំក្នុងការកសាងព្រះពុទ្ធបដិមាដ៏ធំ និងខ្ពស់ជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយក៏នឹងស្ថិតក្នុងចំណោមព្រះពុទ្ធបដិមាខ្ពស់ៗនៅលើពិភពលោក។ គម្រោងសាងសង់ព្រះពុទ្ធបដិមានេះដែរ ជាការរក្សានូវអត្តសញ្ញាណ និងសាសនាជាតិ ព្រោះព្រះពុទ្ធបដិមាទាំងនោះនឹងគង់នៅជាសម្បត្តិវប្បធម៌ជាតិតជំនាន់ សម្រាប់ជាទីសក្ការៈដ៏ឧដុង្គឧត្តមរបស់ពុទ្ធសាសនិកជនទាំងអស់គ្នានិងទុកជាស្នាដៃនៃកេរ្តិ៍មរតកដល់កូនចៅជំនាន់ក្រោយ។











## តំណាងសមាគមឧកញ៉ាកម្ពុជាចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមរៀបចំកិច្ចប្រជុំជាមួយនឹងប្រទេសថៃស្តីពី "តំបន់សេដ្ឋកិច្ចពិសេសបំពេញបន្ថែមគ្នារវាងកម្ពុជានិងថៃ"

នាព្រឹកថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា តំណាង អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមរៀបចំកិច្ចប្រជុំជាមួយនឹងប្រទេសថៃស្តីពី «តំបន់សេដ្ឋកិច្ចពិសេសបំពេញបន្ថែមគ្នារវាងកម្ពុជានិងថៃ» ដែលបានប្រព្រឹត្តទៅនៅវិមានសន្តិភាពក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសដោយមានសមាសភាពចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រនិងនវានុវត្តន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាគមឧកញ៉ាកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា និងតំណាងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញផងដែរ។

ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍សង្ខេបពីសាវតារនៃគំនិតផ្តួចផ្តើមឱ្យមានកិច្ចពិភាក្សានៅថ្ងៃនេះ ថែមទាំងបើកវេទិការដល់អង្គប្រជុំទាំងមូលដើម្បីចូលរួមផ្តល់ជាគំនិតក្នុងការជជែកពិភាក្សាជាមួយនឹងភាគីប្រទេសថៃឱ្យទទួលបានផ្លែផ្កាល្អប្រសើរ។

អ្នកឧកញ៉ា ហ៊ុន ឡាក់ បានជម្រាបជូនអង្គប្រជុំទាំងមូលនូវសក្តានុពលនៃការវិនិយោគនៃសមាជិកសមាគមឧកញ៉ាកម្ពុជាក្នុងវិស័យជាច្រើនក្នុងនោះក៏មានការវិនិយោគអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនេះដែរ។អ្នកឧកញ៉ាបានផ្តល់នូវធាតុចូលសំខាន់ៗមួយចំនួនពាក់ព័ន្ធចំនុចប្រឈមខ្វះខាត និងផ្តល់គំនិតធ្វើឱ្យប្រសើរបន្ថែមដើម្បីទាក់ទាញវិនិយោគិនចូលរួមអភិវឌ្ឍន៍ក្នុងតំបន់សេដ្ឋកិច្ចពិសេស ទន្ទឹមនឹងនោះអ្នកឧកញ៉ាក៏បានមានប្រសាសន៍បន្ថែមទៀតផងដែរថាអ្នកឧកញ៉ាប្រធានសមាគមនិងសមាជិកមួយចំនួនដែលបាននឹងកំពុងវិនិយោគអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស បានត្រៀមខ្លួនរួចជាស្រេចក្នុងការជួយជ្រោមជ្រែងការងារពាក់ព័ន្ធទៅនឹង "តំបន់សេដ្ឋកិច្ចពិសេសបំពេញបន្ថែមគ្នារវាងកម្ពុជានិងថៃ" នេះដើម្បីចូលរួមជាធាតុផ្សំមួយយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។













# ថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសក លី ហាក់ស្រ៊ុន ដែលត្រូវជាឪពុកបង្កើតរបស់ អ្នកឧកញ៉ា អ៊ឹង លីហេង សមាជិកសកម្មនៃសមាគមឧកញ៉ាកម្ពុជា

នារសៀលថ្ងៃព្រហស្បតិ៍ ១២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជារួមមាន៖ អ្នកឧកញ៉ា ហ៊ុន ឡាក់ ,ឧកញ៉ា ម៉ិល សារឿន, ជំទាវឧកញ៉ា ទី គឹមស្រ៊ាន,អ្នកឧកញ៉ា ហេង សៀ និងឧកញ៉ា តាំង គីមថុង អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសក លី ហាក់ស្រ៊ុន ដែលត្រូវជាឪពុកបង្កើតរបស់ អ្នកឧកញ៉ា អ៊ឹង លីហេង សមាជិកសកម្មនៃសមាគមឧកញ៉ាកម្ពុជា ដែលបានប្រារព្ធពិធីបុណ្យសពនៅគេហដ្ឋានក្នុងបុរីប៉េងហួត បឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ក្នុងវេលាប្រកបដោយទុក្ខព្រួយដ៏សោកសង្រេងជាទីបំផុតនេះ អ្នកឧកញ៉ា ផៃ ហុកឈួន បាននាំយកនូវលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនចំពោះអ្នកឧកញ៉ា អ៊ឹង លីហេង និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ដោយសេចក្ដីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់អ្នកមានគុណមួយរូបជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅក្រៃលែងបំផុតដែលពោរពេញដោយព្រហ្មវិហារធម៌និងបានលះបង់បូជាអស់កម្លាំងកាយកម្លាំងចិត្តគ្រប់សព្វបែបយ៉ាងក្នុងការបីបាច់ថែរក្សា បុត្រា បុត្រី ចៅប្រុស ចៅស្រី ឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ។ សូមឧទ្ទិសបួងសួងដល់ ដួងវិញ្ញាណក្ខន្ធ ឧបាសក លី ហាក់ស្រ៊ុន សូមបានទៅកាន់ឋានបរមសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។







## កិច្ចប្រជុំធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា តំណាង អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន៩រូប ចូលរួមកិច្ចប្រជុំពិភាក្សាធុរកិច្ចជាមួយលោកជំទាវវេជ្ជបណ្ឌិតDevyani.U.Khobragadeឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជានៅស្ថានទូតផ្ទាល់នារាជធានីភ្នំពេញ។

កិច្ចប្រជុំដ៏សំខាន់នេះ មានគោលបំណងពិភាក្សាលើការរៀបចំផែនការជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងវិស័យឯកជនកម្ពុជា-ឥណ្ឌា ឱ្យកាន់តែមានភាពសកម្មនិងល្អប្រសើរឈានទៀងថែមមួយកម្រិតទៀតលើវិស័យដែលមានសក្តានុពលដើម្បីជាការចូលរួមចំណែកដល់ការលើកកម្ពស់ពាណិជ្ជកម្មនៃវិនីយោគិនប្រទេសទាំងពីរ។បន្ថែមលើនេះកិច្ចប្រជុំក៏បានពិភាក្សាផងដែរលើរបៀបវារៈសំខាន់ៗរួមមានទី១ការរៀបចំយន្តការទំនាក់ទំនងរវាងក្រុមលេខាធិការដ្ឋានសមាគមឧកញ៉ាកម្ពុជា និងសហព័ន្ធនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌានៃក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា ដើម្បីធានាបាននូវយន្តការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងជាប់លាប់ក្នុងការផ្លាស់ប្តូរ និងចែករំលែកទៅវិញទៅមកនូវព័ត៌មានធុរកិច្ចសំខាន់ៗពាក់ព័ន្ធពាណិជ្ជកម្ម និងការវិនិយោគនៃប្រទេសទាំងពីរ និងទី២ការកំណត់ប្រភេទក្រុមហ៊ុននិងវិស័យជាក់លាក់ដែលភាគីទាំងពីរមានចំណាប់អារម្មណ៍ធ្វើការផ្គូរផ្គងដើម្បីជាឱកាសសម្រាប់ធុរជន/វិនិយោគិនកម្ពុជា-ឥណ្ឌា អាចសិក្សាក៏ដូចជាការចាប់ដៃគូវិនិយោគរួមគ្នា។

សូមជម្រាបផងដែរថាកិច្ចប្រជុំនេះបានរៀបចំឡើងបន្ទាប់ពីសមាគមឧកញ៉ាកម្ពុជានិងសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មឥណ្ឌាបានប្រកាសសម្ពោធជាផ្លូវការនូវ "ក្រុមលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធុរកិច្ចរួមឥណ្ឌា-កម្ពុជា" ព្រមទាំងបានរៀបចំកិច្ចប្រជុំលើកដំបូងរបស់ខ្លួនផងដែរ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ នៅរដ្ឋធានីញូវដេលីនៃសាធារណរដ្ឋឥណ្ឌា។







# សមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមកម្មវិធី
## “India-Cambodia Chemical Business Meet”

នាថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ សមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ៨រូបព្រមទាំងសហការីបានអញ្ជើញចូលរួមក្នុងកម្មវិធី “India-Cambodia Chemical Business Meet” ដែលសហការរៀបចំឡើងដោយស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា, សមាគមសភាពាណិជ្ជកម្មឥណ្ឌានៅកម្ពុជា, និង Basic Chemicals, Cosmetics & Dyes Export Promotion Council ដោយប្រព្រឹត្តទៅនៅសណ្ឋាគារ Hyatt Regency Phnom Penh ក្នុងគោលបំណងធ្វើសន្ទានកម្មរវាងធុរជន និងវិនិយោគិនក្នុងស្រុកជាមួយសហគ្រាសដែលអញ្ជើញមកពីប្រទេសឥណ្ឌា សំដៅពង្រឹង និងពង្រីកការផ្សារភ្ជាប់បណ្តាញលើប្រតិបត្តិការធុរកិច្ចជាពិសេសការផ្គូផ្គងធុរកិច្ចកម្ពុជា-ឥណ្ឌាលើវិស័យសារធាតុគីមីដែលបម្រើដល់ខ្សែច្រវាក់ផលិតកម្មនៃរោងចក្រ និងកម្មន្តសាល។

កម្មវិធីនេះមានការអញ្ជើញចូលរួមផ្តល់កិត្តិយសពីសំណាក់ លោកជំទាវ Devyani Khobragade ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា, តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងវិស័យឯកជនកម្ពុជា-ឥណ្ឌាសរុបប្រមាណ ៨០រូប។









# ថ្នាក់ដឹកនាំនិងសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៨ នាទឹកដីខេត្តសៀមរាប

នារសៀលថ្ងៃសៅរ៍ ៧កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំអ្នកឧកញ៉ា និងឧកញ៉ាចំនួន១២រូបទៀតជាថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលរួមពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៨នាទឹកដីខេត្តសៀមរាបក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត។**

គោលបំណងនៃពិធីបុណ្យទន្លេ គឺដើម្បីជំរុញលើកតម្លៃ និងផ្សព្វផ្សាយសក្តានុពលទេសចរណ៍ខេត្តនានា តាមដងទន្លេ ជាពិសេស លើកទឹកចិត្តដល់ប្រជាជន នៅតាមបណ្តាខេត្តទាំងនោះ ឱ្យចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍទីក្រុងជាប់ដងទន្លេ និងការងារអភិវឌ្ឍទេសចរណ៍សហគមន៍។ បុណ្យទន្លេមានតួនាទីយ៉ាសំខាន់ ដើម្បីបំផុសចលនាមហាជនឱ្យចូលរួមក្នុងការអភិរក្ស និងអភិវឌ្ឍន៍ធនធានទន្លេប្រកបដោយនិរន្តរភាព និងចូលរួមសម្រេចយុទ្ធសាស្ត្រពិពិធកម្មទេសចរណ៍ឱ្យកាន់តែសំបូរបែប ទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាកម្ពុជា ឱ្យបានកាន់តែច្រើនថែមទៀត។

















ក្នុងនោះផងដែររាជរដ្ឋាភិបាលក៏បានកំណត់យកខេត្តសៀមរាបជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ដែលមានលក្ខណៈពហុវិស័យ ក្នុងចំណោមប៉ូលទាំង៥ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចទៅក្នុងសៀមរាប និងខេត្តដទៃទៀត ជាពិសេស វិស័យទេសចរណ៍ តាមរយៈការទាក់ទាញពីសក្តានុពលពីខេត្តសៀមរាប តភ្ជាប់ទៅកាន់សក្តានុពល និងគោលដៅទេសចរណ៍សំខាន់ៗដទៃទូទាំងប្រទេសដែលតម្រូវឱ្យដាក់ចេញនូវវិធានការណ៍ពិសេសនិងគន្លឹះក្នុងការទាក់ទាញក្នុងឆ្នាំ២០២៤ សម្រាប់កម្ពុជា ដោយកម្ពុជាបានដាក់ចេញនូវយុទ្ធនាការ "ទស្សនាសៀមរាប ឆ្នាំ២០២៤" និងត្រូវបានប្រកាសកាលពីថ្ងៃទី១៣ខែវិច្ឆិកាឆ្នាំ២០២៣ក្នុងវេទិការដ្ឋាភិបាល-ឯកជនលើកទី១៩នៅវិមានសន្តិភាពដោយមានវិធានការចំនួន ៨ ក្នុងការស្តារវិស័យទេសចរណ៍ខេត្តសៀមរាបរួមមាន៖

១.ការរៀបចំឡើងវិញក្រុមប្រឹក្សាទេសចរណ៍

២.ការរៀបចំ និងដាក់ចេញផែនការសកម្មភាពជាក់លាក់ «**ទស្សនាសៀមរាប ឆ្នាំ២០២៤**»

៣.រៀបចំបដិសណ្ឋារកិច្ចតាមច្រកព្រំដែន

៤.ការពង្រីកវិសាលភាពបណ្តុព្រំដែន

៥.ការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប

៦. ការលើកទឹកចិត្តផ្នែកពន្ធដារ

៧.លើកលែងការពិន័យអន្តរការណ៍ជាប្រាក់ចំពោះការហួសសុពលភាពអាជ្ញាបណ្ណមគ្គុទ្ទេសក៏ទេសចរណ៍និងអ្នកបកប្រែភាសាបន្តពីមគ្គុទ្ទេសក៏ទេសចរណ៍

៨.ការតភ្ជាប់ជើងហោះហើរដោយត្រង់ពីគោលដៅទេសចរណ៍ល្បីមកសៀមរាប ។

# ជំនួបពិភាក្សារវាងសមាគមឧកញ៉ាកម្ពុជា និងឯកឧត្តមឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំង ស្តីពីការរៀបចំវេទិកាធុរកិច្ចកម្ពុជា-បារាំងលើកទី២

នារសៀលថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមទាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល បានទទួលស្វាគមន៍ ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី នាទីស្នាក់ការសមាគមឧកញ៉ាកម្ពុជានៅសណ្ឋាគារភ្នំពេញក្នុងជំនួបពិភាក្សាស្តីពីការរៀបចំវេទិកាធុរកិច្ចកម្ពុជា-បារាំង។

ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ា លី យ៉ុងផាត់ បានថ្លែងមតិស្វាគមន៍ និងថ្លែងអំណរគុណចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតព្រមទាំងសហការីដែលបានចូលរួមក្នុងជំនួបដ៏មានសារៈសំខាន់នេះដើម្បីពិភាក្សាលម្អិតលើរបៀបវារៈដែលបានស្នើឡើងជាពិសេសកិច្ចសហការក្នុងការរៀបចំវេទិកាកម្ពុជា-បារាំងនាពេលខាងមុខនេះតែម្តង។ជាកិច្ចបន្តអ្នកឧកញ៉ា ហ៊ុន ឡាក់ បានធ្វើបទបង្ហាញសង្ខេបអំពីប្រវត្តិសមាគម តួនាទី និងភារកិច្ចស្នូលសំខាន់ៗនៃសមាគមឧកញ៉ាកម្ពុជាជូនដល់ឯកឧត្តមឯកអគ្គរដ្ឋទូតនិងសហការីបានជ្រាប។បន្ទាប់មកអ្នកឧកញ៉ាប្រធានបានផ្តល់វេទិកាជូនដល់អង្គប្រជុំទាំងមូលដើម្បីពិភាក្សា និងផ្តល់ធាតុចូលឱ្យបានស៊ីជម្រៅទៅតាមរបៀបវារៈនីមួយៗ។

ជាការឆ្លើយតប ឯកឧត្តមឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណ និងកោតសរសើរអ្នកឧកញ៉ាប្រធានក៏ដូចជាថ្នាក់ដឹកនាំសមាគមឧកញ៉ាកម្ពុជាដែលបានរៀបចំឱ្យមានជំនួបដ៏សំខាន់នៅនេះ ជាពិសេស ឯកឧត្តមបានបង្ហាញពីសុទិដ្ឋិនិយមក្នុងកិច្ចសហការគ្នារវាងសមាគមឧកញ៉ាកម្ពុជា និងសភាពាណិជ្ជកម្មបារាំងប្រចាំនៅកម្ពុជាដើម្បីរៀបចំវេទិកាធុរកិច្ចកម្ពុជាបារាំងតាមរយៈការជួយគាំទ្រពីស្ថានទូតផ្ទាល់ដោយនឹងចាប់ផ្តើមការងារបន្ទាប់ពីកិច្ចប្រជុំនៅថ្ងៃនេះតទៅ។

សូមបញ្ជាក់ថាអង្គប្រជុំទាំងមូលបានជជែកពិភាក្សានិងផ្តល់ធាតុចូលលើខ្លឹមសារនៃរបៀបវារៈទាំងនោះយ៉ាងផុសផុលប្រកបដោយឆន្ទៈមោះមុតជាពិសេសភាគីទាំងសងខាងបានលើកនិងទទួលយកនូវសំណើទាំងអស់ដើម្បីធ្វើយ៉ាងណាជំរុញឱ្យកិច្ចប្រជុំនៅថ្ងៃនេះទទួលបានលទ្ធផលផ្លែផ្កា និងបង្កើតឱ្យមានយន្តការក្រុមការងារសម្រាប់រៀបចំការងារបន្តទៀត។








## ពិធីបើកសម្ពោធជាផ្លូវការនៃ<br>“ពិព័រណ៍គ្រឿងអលង្ការ និងត្បូងកម្ពុជា-អន្តរជាតិ លើកទី១៥ ឆ្នាំ២០២៤”

នារសៀលថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន១៤រូបចូលរួមក្នុងពិធីបើកសម្ពោធជាផ្លូវការនៃ**«ពិព័រណ៍គ្រឿងអលង្ការ និងត្បូងកម្ពុជា-អន្តរជាតិ លើកទី១៥ ឆ្នាំ២០២៤»** ក្រោមអធិបតីភាពតំណាងថ្នាក់ដឹកនាំនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក្រសួងកិច្ចការនារីនិងក្រសួងពាណិជ្ជកម្ម។នេះជាលើកទី១៥ហើយដែលពិព័រណ៍នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបន្តពង្រឹងនិងជំរុញការអភិវឌ្ឍវិស័យគ្រឿងអលង្ការឱ្យមានការរីកចម្រើនព្រមទាំងចូលរួមផ្សព្វផ្សាយត្បូងមានតម្លៃកម្ពុជាទៅកាន់ពិភពលោកដោយមានការចូលរួមការដាក់តាំងបង្ហាញគ្រឿងអលង្ការនិងត្បូងមានតម្លៃជាច្រើនប្រភេទពីបណ្តាពាណិជ្ជករ អាជីវករ និងក្រុមហ៊ុនគ្រឿងអលង្ការជាតិ និងអន្តរជាតិជាដើម។

សូមជម្រាបផងដែរថា ពិព័រណ៍នេះត្រូវបានរៀបចំឡើងដោយសមាគមពាណិជ្ជករគ្រឿងអលង្ការ និងត្បូងមានតម្លៃនៅកម្ពុជារយៈពេលចំនួន ៥ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ ២៥ ខែមីនា ឆ្នាំ២០២៤ អគារ A, B និង C នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្ររាជធានីភ្នំពេញ។










# អ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលវិសាមញ្ញ លើកទី៧ អាណត្តិទី១

នារសៀលថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ នាទីស្នាក់ការសមាគមឧកញ៉ាកម្ពុជានៃសណ្ឋាគារភ្នំពេញសមាគមឧកញ៉ាកម្ពុជាបានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិសាមញ្ញ លើកទី៧ អាណត្តិទី១ ក្រោមអធិបតីភាព អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធាន អង្គប្រជុំ ដោយមានវត្តមានចូលរួមពីសំណាក់ អ្នកឧកញ៉ា អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលចំនួន ១៩រូប រួម នឹងមេធាវីរបស់សមាគម ចំនួន២រូបផងដែរ ដើម្បីពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួន ៣គឺ ៖

- ពិនិត្យនិងផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ភូមិបាល,សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងអនុក្រឹត្យស្តីពីស្តង់ដារគុណវុឌ្ឍិសម្រាប់អ្នកអភិវឌ្ឍន៍អចលនទ្រព្យ។
- ពិភាក្សាលើការរៀបចំសន្និបាតប្រចាំឆ្នាំ២០២៣។
- ពិភាក្សាពីការស្នើបញ្ចូលសមាសភាពក្រុមប្រឹក្សាភិបាលបន្ថែម,ការស្នើឱ្យមានក្រុមទីប្រឹក្សាធុរកិច្ចព្រមទាំងពិភាក្សា ពីបញ្ហានានាជុំវិញគោរមងារឧកញ៉ានៅកម្ពុជានាពេលបច្ចុប្បន្ន។

ជាកិច្ចផ្តើមអ្នកឧកញ៉ាប្រធាន បានស្វាគមន៍ និងថ្លែងអំណរគុណសមាជិកអង្គប្រជុំទាំងមូលដែលបានចូលរួម កិច្ចប្រជុំដ៏មានសារសំខាន់នេះ។ ជាកិច្ចបន្ត អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការបានធ្វើបទបង្ហាញជូនអង្គប្រជុំ ទាំងមូល ទៅតាមរបៀបវារៈដែលបានស្នើឡើង។ សមាជិកអង្គប្រជុំបានពិនិត្យ ពិភាក្សា និងផ្តល់យោបល់ទៅលើ របៀបវារៈទាំងនោះយ៉ាងយកចិត្តទុកដាក់ និងផុសផុល។ ជាលទ្ធផលនៃរបៀបវារៈទី១ អង្គប្រជុំបានឯកភាពឱ្យមាន កិច្ចប្រជុំជាមួយតំណាងមកពីក្រសួងពាក់ព័ន្ធដោយពិភាក្សាលម្អិតលើចំណុចសំខាន់ៗនៃច្បាប់ និងអនុក្រឹត្យខាងលើ ជាបន្តទៀត, របៀបវារៈទី២៖ អង្គប្រជុំបានឯកភាពលើការកំណត់កាលបរិច្ឆេទទីតាំង សមាសភាពចូលរួម និង របៀបវារៈនៃសន្និបាត ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ នាពេលខាងមុខនេះ, និងរបៀបវារៈ ផ្សេងៗអង្គប្រជុំបានឯកភាពលើការបន្ថែមចំនួនសមាសភាពក្រុមប្រឹក្សាភិបាល និងរៀបចំឱ្យមានក្រុមទីប្រឹក្សាធុរកិច្ច ស្របតាមកំណើននៃទំហំការងារភាពរីកចម្រើននិងសកម្មភាពដ៏មមាញឹករបស់សមាគមក្នុងពេលបច្ចុប្បន្ននិងអនាគត

កិច្ចប្រជុំបានបិទបញ្ចាប់នៅវេលាម៉ោង១៨:០០នាទីក្នុងកាលបរិច្ឆេទដដែលដោយទទួលបានលទ្ធផលផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

























# វេទិកា Maekyung កម្ពុជា ក្រោមប្រធានបទ៖ “ព្រះរាជាណាចក្រពោរពេញដោយកាលានុវត្តភាព៖ កិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រដើម្បីរុញច្រានកំណើនសម្រាប់អនាគត”

នាព្រឹកថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងអ្នកឧកញ៉ា លី យ៉ុងផាត់ បានដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបចូលរួមក្នុងវេទិកាMaekyungកម្ពុជាក្រោមប្រធានបទ៖ព្រះរាជាណាចក្រពោរពេញដោយកាលានុវត្តភាព៖កិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រដើម្បីរុញច្រានកំណើនសម្រាប់អនាគតដែលត្រូវបានសហការរៀបចំឡើងដោយក្រុមហ៊ុន Maekyung Media Group, ទីភ្នាក់ងារជំរុញពាណិជ្ជកម្ម-វិនិយោគកូរ៉េ (KOTRA), និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងគោលបំណងចែករំលែកព័ត៌មានអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗ ព្រមទាំងសក្តានុពល និងកាលានុវត្តភាពវិនិយោគ និងធុរកិច្ចនៅកម្ពុជា ជាពិសេសការស្វែងរកកិច្ចសហការ និងភាពជាដៃគូរវាងវិស័យឯកជនកម្ពុជា-កូរ៉េ។

កម្មវិធីដ៏អធិកអធមដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, និងភ្ញៀវកិត្តិយសតំណាងក្រសួង ស្ថាប័ន និងវិស័យឯកជនសរុបប្រមាណ ២៦០រូបនេះ មានប្រធានបទចំនួន ៣ ត្រូវបានជ្រើសរើសមកធ្វើបទឧទ្ទេសនាមជូនអង្គវេទិការួមមាន៖

- ទី១៖ បរិយាកាសវិនិយោគនៅកម្ពុជាដោយ ឯកឧត្តម សួន សុផល អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា និង ឯកឧត្តម Allen Tan ទីប្រឹក្សាអមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
- ទី២៖ ករណីសិក្សាស្តីពីភាពជោគជ័យនៃសហគ្រាសកូរ៉េនៅកម្ពុជាដោយ ឯកឧត្តមបណ្ឌិត កាន ច័ន្ទមេត្តា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- ទី៣៖ យុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកូរ៉េ-កម្ពុជាដោយឯកឧត្តម ស៊ីម សុខេង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម, ឯកឧត្តម ឡឹក សុជា អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឧកញ៉ា ភូ សេតុង នាយកប្រតិបត្តិ Anco Group, និង លោក Lee Sangyeop នាយកប្រតិបត្តិក្រុមហ៊ុន Barun (Cambodia) Accounting & Consulting Co., Ltd.។









## អ្នកឧកញ៉ា លី យ៉ុងផាត់ រួមទាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល បានទទួលស្វាគមន៍ និងពិភាក្សាធុរកិច្ចជាមួយ លោក Zhong Hong អភិបាលរងទីក្រុងណាននីង និងគណៈប្រតិភូ

នាព្រឹកថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ នាទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា នៃសណ្ឋាគារភ្នំពេញ អ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមទាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល បានទទួលស្វាគមន៍ និងពិភាក្សាធុរកិច្ចជាមួយ លោក Zhong Hong អភិបាលរងទីក្រុងណាននីង និងគណៈប្រតិភូទីក្រុងណាននីង ខេត្តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងពិភាក្សាលើកិច្ចសហប្រតិបត្តិការធុរកិច្ចរវាងក្រុមហ៊ុនកម្ពុជា-ចិន និងការសិក្សាដើម្បីវិនិយោគតំបន់សេដ្ឋកិច្ចពិសេសព្រមទាំងស្វែងយល់បន្ថែមពីបរិយាកាសធុរកិច្ចផ្សេងៗ។

ជាកិច្ចចាប់ផ្តើម អ្នកឧកញ៉ា លី យ៉ុងផាត់ បានថ្លែងស្វាគមន៍ និងបានជម្រាបជូនគណៈប្រតិភូពីទស្សនវិស័យបេសកកម្មនិងតួនាទីស្នូលនៃសមាគមឧកញ៉ាកម្ពុជាជាពិសេសបានរំលេចភាពជាដៃគូនៃសមាគមឧកញ៉ាកម្ពុជាជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ពាណិជ្ជកម្ម និងជំរុញការទាក់ទាញអ្នកវិនិយោគិនមកវិនិយោគនៅកម្ពុជា ព្រមទាំងភាពជាតំណាងឱ្យឧកញ៉ាទាំងអស់នៅកម្ពុជាផងដែរ។ ជាកិច្ចបន្ត អ្នកឧកញ៉ាប្រធាន បានអនុញ្ញាតដល់សមាជិកអង្គប្រជុំទាំងមូលធ្វើការណែនាំខ្លួននិងអាជីវកម្មព្រមទាំងការផ្លាស់ប្តូរមតិយោបល់ទៅវិញទៅមកដោយលើកពីវិស័យអាទិភាពដែលមានសក្តានុពលនៅកម្ពុជា ជាពិសេសការធ្វើបទបង្ហាញពីការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនាងកុក កោះកុង និងកំពង់ផែទឹកជ្រៅដែលអាចទទួលនូវកប៉ាល់ខ្នាតធំចូលមកកំពង់ផែក្នុងខេត្តកោះកុង ផងដែរ។

ជាការឆ្លើយតប លោក Zhong Hong និងគណៈប្រតិភូ បានសម្តែងនូវការចាប់អារម្មណ៍យ៉ាងខ្លាំង និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកឧកញ៉ា លី យ៉ុងផាត់ ដែលបានទទួលស្វាគមន៍រូបលោក និងគណៈប្រតិភូយ៉ាងកក់ក្តៅ។ ជាមួយគ្នានេះដែរ លោកក៏បានបង្ហាញសុទិដ្ឋិនិយមថា កិច្ចប្រជុំនៅថ្ងៃនេះ នឹងក្លាយជាច្រកមួយដ៏សំខាន់ក្នុងការសហប្រតិបត្តិការនៅថ្ងៃខាងមុខ។ ទន្ទឹមនឹងនេះលោក Zhong Hong ក៏បានបង្ហាញពីតំបន់សក្តានុពលនៃទីក្រុងណាននីងតាមរយៈវីដេអូខ្លីជូនដល់អង្គប្រជុំផងដែរ។









ក្រោយពីពិភាក្សាអស់ជិត៣ម៉ោង ជាលទ្ធផលអង្គប្រជុំបានឯកភាពគ្នាដូចតទៅ៖

១-ការចាត់វិស័យសក្តានុពលចំនួន៣ ដើម្បីចាប់ផ្តើមការងារបន្តដូចតទៅ៖

- វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយផ្តោតជាសំខាន់លើដំណាំកៅស៊ូ និងស្វាយចន្ទី
- វិស័យភ័ស្តុភាកម្ម និងការដឹកជញ្ជូន និងសម្របសម្រួលពាណិជ្ជកម្ម ក៏ដូចជាសេវាគយ
- វិស័យកម្មន្តសាល និងការកែច្នៃសម្រាប់នាំចេញ។

បន្ថែមពីនោះភាគីចិនក៏បានផ្តោតសំខាន់លើការប្រមូលដែកចាស់ៗ ដើម្បីកែច្នៃសម្រាប់ការនាំចេញទៅក្រៅប្រទេសផងដែរ ។

២-ការបំពេញទស្សនកិច្ចទៅវិញទៅមក៖

ជាមួយគ្នានេះ លោក Zhong Hong នឹងអញ្ជើញអ្នកឧកញ៉ា លី យ៉ុងផាត់ និងសមាជិកសមាគមឧកញ៉ាកម្ពុជាទៅបំពេញទស្សនកិច្ចនៅទីក្រុងណាននីង និងរោងចក្រនៅថៃនាពេលណាមួយខាងមុខនេះព្រមទាំងនឹងអញ្ជើញវិនិយោគិនចិនដែលស្ថិតនៅក្នុងវិស័យខាងលើមកបំពេញទស្សនកិច្ចនៅកម្ពុជានាពេលខាងមុខនេះផងដែរ។

ជាការឆ្លើយតប អ្នកឧកញ៉ាប្រធាន ក៏នឹងរៀបចំឱ្យមានដំណើរបំពេញទស្សនកិច្ចក្នុងពេលសមស្របណាមួយណាមួយនាពេលខាងមុខនេះផងដែរ។

ជាកិច្ចបញ្ចប់ អ្នកឧកញ៉ាប្រធានបានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនេះ និងជូនពរដល់គណៈប្រតិភូទីក្រុងណាននីង សូមទទួលបានជោគជ័យក្នុងការបំពេញទស្សនកិច្ចនេះ និងសូមធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុខសុវត្ថិភាព។

សមាគមឧកញ៉ាកម្ពុជា (ស.ឧ.ក.) មាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រធានកិត្តិយសអមដោយឥស្សរជនជាន់ខ្ពស់ចំនួន៤រូបទៀតជាអនុប្រធានកិត្តិយសនិងមានអ្នកជំនួញប្រកបដោយសក្ដានុពល៨រូបជាទីប្រឹក្សាជាន់ខ្ពស់។

គិតត្រឹមខែមីនា ឆ្នាំ២០២៤ សមាគមឧកញ៉ាកម្ពុជាមានសមាជិកសរុបចំនួន ៣៧៣រូបដែលកំពុងដឹកនាំ និងគ្រប់គ្រងអាជីវកម្មប្រមាណជាជាង៧១៦ក្រុមហ៊ុន/សហគ្រាសហើយបានបង្កើតការងាររហូតដល់ជាង២៦០.០០០កន្លែងនៅទូទាំងប្រទេសកម្ពុជាដោយគ្របដណ្ដប់គ្រប់វិស័យរួមមាន៖

### វិស័យកសិកម្ម

វិនិយោគលើដំណាំកសិកម្ម(ដំណាំស្រូវ,បន្លែ និងផ្សេងៗ)..............៦០
ចម្ការស្វាយចន្ទី..............៩
កសិដ្ឋានចិញ្ចឹមជ្រូក/គោ..............៣
ចម្ការផ្លែឈើ..............១០
ចម្ការដូងប្រេង..............១
ចម្ការកៅស៊ូ..............១៤
ចម្ការអំពៅ..............៣

### វិស័យឧស្សាហកម្ម

រោងចក្រផលិតស្រាបៀរ និងភេសជ្ជៈ..............៣
រោងចក្រផលិតស៊ីម៉ងត៍និងផ្គត់ផ្គង់ស៊ីម៉ងត៍..............១០
រោងចក្រកាត់ដេរ..............៨
វារីអគ្គិសនី..............២
រោងចក្រផលិត និងផ្គត់ផ្គង់ឱសថ..............៦
រោងចក្រផលិតទឹកបរិសុទ្ធ..............៥
រុករក និងចម្រាញ់រ៉ែ..............៦

### វិស័យអាហរណ៍ នីហរណ៍

នាំចូល និងចែកចាយយានយន្ត..............៧
នាំចូល និងចែកចាយភេសជ្ជៈ..............១៨
នាំចូល និងផ្គត់ផ្គង់កុំព្យូទ័រ..............៤
ផ្គត់ផ្គង់គ្រឿងសម្អាង..............៧
នាំចូល និងផ្គត់ផ្គង់អាហារ/គ្រឿងឧបភោគបរិភោគ..............២០
នាំចូល និងផ្គត់ផ្គង់គ្រឿងសង្ហារឹម/សម្ភារក្នុងផ្ទះ..............១១
នាំចូល និងចែកចាយផ្លែឈើ..............១
នាំចូល និងចែកចាយគ្រឿងយន្ត..............៩
ផ្គត់ផ្គង់ផលិតផលអាហារបំប៉ន..............៤
ផ្គត់ផ្គង់ប្រេងឥន្ធនៈ និងឧស្ម័ន..............១៤
ចែកចាយគ្រឿងបន្លាស់ទូរសព្ទ..............២
នាំចេញ និងផ្គត់ផ្គង់អង្ករ..............៥
នាំចូល និងចែកចាយដែក..............៥
ផ្គត់ផ្គង់ថ្ម និងម៉ាប..............៦

### វិស័យសេវាកម្ម

គ្រប់គ្រងអាកាសយានដ្ឋាន..............៦
គ្រប់គ្រង..............១៤
ហិរញ្ញវត្ថុ និងធនាគារ..............២៤
មជ្ឈមណ្ឌលពាណិជ្ជកម្ម និងផ្សារទំនើប..............១២
ភោជនីយដ្ឋាន និងហាងកាហ្វេ..............២៧
លក់រាយយានយន្ត..............២
សំណង់ និងកសាងហេដ្ឋារចនាសម្ព័ន្ធ..............៤៤
ផ្គត់ផ្គង់ និងលក់រាយសម្ភារសំណង់..............១៥
ចែកចាយ និងលក់រាយសម្លៀកបំពាក់..............៥
សេវាកម្មសម្អាត..............១
មជ្ឈមណ្ឌលថែរក្សាសម្រស់..............២
អាជីវកម្ម E-Commerce..............៣
វិស័យអប់រំ..............៧
ផ្គត់ផ្គង់គ្រឿងអេឡិចត្រូនិច..............៦
ផ្គត់ផ្គត់អគ្គិសនី..............៤
សេវាកម្មជម្រើសរើសពលករ..............៤
ផ្គត់ផ្គង់កញ្ចក់..............២
សណ្ឋាគារ និងរីសត..............៥៥
មន្ទីរពេទ្យ និងគ្លីនិក..............៥
ធានារ៉ាប់រង..............៣
លក់គ្រឿងអលង្ការ..............៥
សេវាកម្មផ្នែកកិច្ចការច្បាប់..............៤
សេវាកម្មដឹកជញ្ជូនទំនិញ..............១៩
ប្រព័ន្ធផ្សព្វផ្សាយ និងកម្សាន្ត..............៥
ផ្គត់ផ្គង់និងចែកចាយវ៉ែនតា..............១
អភិវឌ្ឍន៍អចលនទ្រព្យ..............១២៦
កំពង់ផែ និងផែស្ងួត..............៦
គ្រឿងបន្លាស់កុំព្យូទ័រ និងបច្ចេកវិទ្យា..............៤
ថាមពលសូឡា..............១
តំបន់សេដ្ឋកិច្ចពិសេស..............១១
សម្ភារសិក្សា និងការិយាល័យ..............៤
ប្រឹក្សាផ្នែកហិរញ្ញវត្ថុ..............១៦
ភ្នាក់ងារទេសចរណ៍..............៩
ដឹកជញ្ជូនអ្នកដំណើរ..............១៥

**សរុបមានចំនួន ៧១៦ ក្រុមហ៊ុន/សហគ្រាស**

## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ:

Website Facebook Telegram Youtube TikTok


ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org


សូមអរគុណ!